ធនាគារជាតិនៃកម្ពុជា

ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# របាយការណ៍ប្រចាំឆ្នាំ២០២២
# ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា



សាកសិទ្ធភាព នវានុវត្តន៍ និងបរិយាបន្ន

# អារម្ភកថា

ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងនវានុវត្តន៍ បាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ ដែលជាកត្តារួមចំណែកដល់ការអភិវឌ្ឍវិស័យ ហិរញ្ញវត្ថុនិងសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ ក៏ដូចជាគាំទ្រការអនុវត្តក្របខណ្ឌគោលនយោបាយ សេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានធ្វើទំនើបកម្មចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ២០១០ មក ហើយ សមិទ្ធផលថ្មីៗត្រូវបានអភិវឌ្ឍ និងដាក់ឱ្យដំណើរការជាបន្តបន្ទាប់ ជាពិសេស ប្រព័ន្ធទូទាត់រាយជា អេឡិចត្រូនិក ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងនិន្នាការអភិវឌ្ឍក្នុងតំបន់ ព្រមទាំង ការផ្លាស់ប្តូរឥរិយាបថរបស់អ្នកប្រើប្រាស់។ ជាក់ស្តែង ការដាក់ឱ្យដំណើរការប្រព័ន្ធបាគងកាលពី ឆ្នាំ២០២០ កន្លងទៅ ជាជំហានថ្មីមួយដែលបានជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ជាឌីជីថល និងផ្តល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាទូទាត់សងប្រាក់តាមរយៈសេវា ហិរញ្ញវត្ថុផ្លូវការបានកាន់តែទូលំទូលាយ និងប្រសើរជាងមុន។ បន្ថែមពីនេះ ប្រព័ន្ធបាគងបានសម្រួល ដល់ប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់ក្នុងការទិញ-លក់ទំនិញនិងសេវា ជាពិសេស ក្នុងអំឡុងពេលនៃការ រីករាលដាលនៃជំងឺកូវីដ-១៩ ដែលរួមចំណែកឱ្យអាជីវកម្មទាំងឡាយអាចបន្តនិរន្តរភាពជាប្រក្រតីបាន តាមប្រព័ន្ធអនឡាញ។

គួរកត់សម្គាល់ថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះសេវាទូទាត់ និងផ្ទេរប្រាក់ឌីជីថលថ្មីៗ ដូចជាការទូទាត់ និងផ្ទេរប្រាក់តាមរយៈឃ្យូអរកូត និងលេខទូរស័ព្ទ ទទួលបានការពេញនិយមប្រើប្រាស់ ពីសំណាក់ប្រជាជនកម្ពុជា ជាពិសេសយុវវ័យ។ ទំហំនៃការទូទាត់ឌីជីថលក្នុងឆ្នាំ២០២២ មានការ កើនឡើង ៣២,៧% ធៀបនឹងឆ្នាំ២០២១ និងសមមាត្រប្រមាណ ១៥ ដង នៃផលិតផលក្នុងស្រុកសរុប។ ដើម្បីជំរុញឱ្យការទូទាត់តាមមធ្យោបាយនេះកាន់តែមានលក្ខណៈងាយស្រួល និងមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ខេអេចឃ្យូអរកូត ដែលជាស្តង់ដារឃ្យូអរកូតសម្រួល ដល់ការទូទាត់ឆ្លងគ្រឹះស្ថាន និងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់អ្នកប្រើប្រាស់។ ការដាក់ឱ្យ ដំណើរការប្រព័ន្ធបាគង និងស្តង់ដារឃ្យូអរកូតបានផ្តល់លទ្ធភាពឱ្យប្រទេសកម្ពុជាត្រៀមខ្លួនរួចជាស្រេច ក្នុងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់ ដូចដែលបានអនុវត្តរួចហើយជាមួយប្រទេសថៃ និងប្រទេសម៉ាឡេស៊ី និងកំពុងបន្តអនុវត្តជាមួយប្រទេសវៀតណាម និងប្រទេសឡាវបន្ថែមទៀត។

ក្រៅពីការអភិវឌ្ឍប្រព័ន្ធទូទាត់ឌីជីថល ការរីកចម្រើនផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុក៏បានផ្តល់ ឱកាសជាច្រើនទៀតដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការដាក់ឱ្យប្រើប្រាស់សេវាហិរញ្ញវត្ថុ ផ្សេងៗទៀតក្នុងទីផ្សារ។ ជាក់ស្តែង ការដាក់ឱ្យប្រើប្រាស់កម្មវិធីធនាគារតាមរយៈទូរស័ព្ទឆ្លាតវៃ ជាសេវាហិរញ្ញវត្ថុឌីជីថលដែលកំពុងពេញនិយម ដែលផ្តល់លទ្ធភាពឱ្យអតិថិជនអាចធ្វើប្រតិបត្តិការ ធនាគារដោយខ្លួនឯងបានតាមអនឡាញ ជាពិសេសទៅលើប្រតិបត្តិការដូចជា ការបើកគណនី

ការដាក់ប្រាក់សន្សំ ការស្នើសុំនិងទទួលឥណទាន និងការទូទាត់សងប្រាក់ជាដើម។ ការរីកចម្រើនទាំងនេះបានក្លាយជាចលករដ៏សំខាន់មួយ ក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលដូចជា ការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់ជាដើម និងក្លាយជាកត្តាមួយដ៏សំខាន់ក្នុងការជួយគាំទ្រនិងជំរុញសកម្មភាពធុរកិច្ច ដែលនឹងចូលរួមចំណែកក្នុងការស្តារសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីវិបត្តិជំងឺកូវីដ-១៩។

សមិទ្ធផលគួរជាទីមោទនៈទាំងនេះ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការដាក់ចេញគោលនយោបាយ និងបទប្បញ្ញត្តិ ព្រមទាំងអនុវត្តការត្រួតពិនិត្យ ដើម្បីគាំទ្រនិងជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងចីរភាព។ ម្យ៉ាងទៀត ស្ថិតក្នុងយុគសម័យឌីជីថល ការអភិវឌ្ឍទាំងនេះក៏មិនអាចខ្វះបាននូវកិច្ចសហការល្អពីអាជ្ញាធរពាក់ព័ន្ធក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងអត្តសញ្ញាណឌីជីថល ដើម្បីគាំទ្រឱ្យប្រព័ន្ធទូទាត់សងប្រាក់ដំណើរការដោយពិលាស មានសុវត្ថិភាព និងប្រសិទ្ធភាព។ ទន្ទឹមនោះ ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថលជាផ្នែកសំខាន់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីជំរុញការទទួលយក និងប្រើប្រាស់សេវាធនាគារឌីជីថលប្រកបដោយសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់ការបំពេញភារកិច្ចរបស់មន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់។ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីពាក់ព័ន្ធ និងក្រសួង-ស្ថាប័នផ្សេងៗ ព្រមទាំងដៃគូអភិវឌ្ឍនានា ដែលបានរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជាឱ្យមានការរីកចម្រើន។ ខ្ញុំមានសេចក្តីជឿជាក់យ៉ាងមុតមាំថា របាយការណ៍ប្រចាំឆ្នាំ២០២២ ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជានេះ នឹងក្លាយជាឯកសារដ៏មានសារៈសំខាន់សម្រាប់សាធារណជនទាំងអស់ សិក្សាស្វែងយល់បន្ថែមពីការងារដែលធនាគារជាតិនៃកម្ពុជាកំពុងអនុវត្តវឌ្ឍនភាពថ្មីៗស្តីពីការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា និងទិសដៅនាពេលអនាគត។

ទេសាភិបាល

ជា.ចាន់តូ

# មាតិកា


អារម្ភកថា | i

បញ្ជីតារាង ប្រអប់ និងក្រាហ្វ | iv

អក្សរកាត់ | vi

បរិយាយសង្ខេប | viii

ស្ថិតិអំពីស្ថានភាពសេវាទូទាត់សងប្រាក់ | xii

១ វឌ្ឍនភាពរបស់ប្រព័ន្ធទូទាត់សងប្រាក់ | ១

ការអភិវឌ្ឍចម្បងៗ | ១

គោលនយោបាយគាំទ្រ | ៤

ជំហានបន្ទាប់ | ៨

២ នវានុវត្តន៍ប្រព័ន្ធបាគង | ១១

វឌ្ឍនភាព | ១១

សមិទ្ធផល | ១៣

៣ ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់ | ២៤

ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់ | ២៤

ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ | ៣៥

ស្តង់ដារឧបករណ៍ និងបណ្តាញប្រព័ន្ធទូទាត់សងប្រាក់ | ៣៧

៤ ការគ្រប់គ្រងសេវាទូទាត់សងប្រាក់ និងការផ្ទេរប្រាក់ឆ្លងដែន | ៤០

ការគ្រប់គ្រងសេវាទូទាត់សងប្រាក់ | ៤០

ការទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែន | ៤៩

៥ ឧបសម្ព័ន្ធ | ៥៤

ឧបសម្ព័ន្ធ ១ ៖ ច្បាប់ និងបទប្បញ្ញត្តិ | ៥៤

ឧបសម្ព័ន្ធ ២ ៖ បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង | ៥៦

ឧបសម្ព័ន្ធ ៣ ៖ បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៥៧

ឧបសម្ព័ន្ធ ៤ ៖ គ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក | ៦២

ឧបសម្ព័ន្ធ ៥ ៖ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបាគង | ៦៤

# បញ្ជីតារាង ប្រអប់ និងក្រាហ្វ

## តារាង


តារាង ១ - ប្រតិបត្តិការទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ................................ ១៥

តារាង ២ - ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី .................. ១៦

តារាង ៣ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់រៀល ........................................ ២៥

តារាង ៤ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក ........................... ២៥

តារាង ៥ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធផាត់ទាត់ជាតិ ...................................................... ២៧

តារាង ៦ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធ FAST ................................................................ ២៩

តារាង ៧ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធ CSS ...................................................... ៣០

តារាង ៨ - ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្ដាលតាមប្រព័ន្ធ OBS ............................ ៣២

តារាង ៩ - ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្ដាលទៅសាខារាជធានី-ខេត្ត តាមប្រព័ន្ធ OBS...... ៣២

តារាង ១០ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT .......................................... ៣៤


## ប្រអប់


ប្រអប់ ១ - ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ............................................................................ ១០

ប្រអប់ ២ - ការអភិវឌ្ឍមុខងារចុះឈ្មោះអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង ................. ២១

ប្រអប់ ៣ - ការអភិវឌ្ឍមុខងារបង្ហាញព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងប្រព័ន្ធបាគង ............ ២២

ប្រអប់ ៤ - ការអភិវឌ្ឍស្តង់ដារខេអេចឃ្យូអរកូត (KHQR Code) ............................................ ២៣


## ក្រាហ្វ


ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរណ៍ និងទំហំប្រាក់ទូទាត់តាមអេឡិចត្រូនិកជាប្រាក់រៀល ............... ២

ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈការស្កេន QR Code និងប័ណ្ណទូទាត់ ............................. ៣




ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់ជាមួយកម្មវិធីបាគង ........................................ ១២

ក្រាហ្វ ៤ - ប្រតិបត្តិការធ្វើឡើងតាមរយៈប្រព័ន្ធបាគង ........................................................ ១២

ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មុនដាក់និងបន្ទាប់ពីបានដាក់ដំណើរការប្រព័ន្ធបាគង ........................................................................................ ១៣

ក្រាហ្វ ៦ - ប្រតិបត្តិការទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ................................. ១៥

ក្រាហ្វ ៧ - ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ................... ១៧

ក្រាហ្វ ៨ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ............................................................ ២៦

ក្រាហ្វ ៩ - បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក .................. ២៨

ក្រាហ្វ ១០ - បញ្ជាឥណទានតាមប្រព័ន្ធ FAST ................................................................... ២៩

ក្រាហ្វ ១១ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធ CSS .................................................... ៣១

ក្រាហ្វ ១២ - ប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធ OBS ........................................................... ៣៣

ក្រាហ្វ ១៣ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT ....................................... ៣៤

ក្រាហ្វ ១៤ - ចំនួន និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា .................. ៣៥

ក្រាហ្វ ១៥ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះអ៊ីវ៉ាឡេត និងអតិថិជន Walk-in របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ........................ ៥១

ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័តតាមកាបូបអេឡិចត្រូនិក (Mobile E-wallet) ........................................................................... ៥១

ក្រាហ្វ ១៧ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ .............................. ៥១

ក្រាហ្វ ១៨ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិតនិងសេវាធនាគារចល័ត ........................................................................................ ៥២

ក្រាហ្វ ១៩ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ) ............. ៥៣

ក្រាហ្វ ២០ - ចំនួនម៉ាស៊ីន ATM និងម៉ាស៊ីន POS ............................................................. ៥៥

ក្រាហ្វ ២១ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code .................... ៥៥

ក្រាហ្វ ២២ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ............................ ៥១

ក្រាហ្វ ២៣ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS ............. ៥៣



# អក្សរកាត់

| | | |
|---|---|---|
| ATM | Automated Teller Machine | ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ |
| BAKONG | BAKONG System | ប្រព័ន្ធបាគង |
| BIN | Bank Identification Number | លេខអត្តសញ្ញាណធនាគារ |
| CAMDX | Cambodia Data Exchange | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |
| CBC | Credit Bureau Cambodia | ការិយាល័យឥណទានកម្ពុជា |
| CBDC | Central Bank Digital Currency | រូបិយវត្ថុឌីជីថលធនាគារកណ្តាល |
| CPSS and IOSCO | Committee on Payment and Settlement Systems and International Organization of Securities Commissions | គណៈកម្មការប្រព័ន្ធទូទាត់ និងផាត់ទាត់និងគណៈកម្មការមូលបត្រអន្តរជាតិ |
| CSS | Cambodian Shared Switch | ប្រព័ន្ធខេមបូឌានស៊ែស្វីច |
| DLT | Distributed Ledger Technology | បច្ចេកវិទ្យាឌីអិលធី |
| ECS | Electronic Clearing System | ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក |
| EMV | Europay, Mastercard, and VISA | ស្តង់ដារអ៊ីអឹមវី |
| FAST | FAST Payment System | ប្រព័ន្ធសេវាទូទាត់រហ័ស |
| FINTECH | Financial Technology | បច្ចេកវិទ្យាហិរញ្ញវត្ថុ |
| ISO | International Organization for Standardization | អង្គការស្តង់ដារអន្តរជាតិ |
| ITMX | Interbank Transaction Management and Exchange | ប្រតិបត្តិករប្រព័ន្ធទូទាត់សងប្រាក់ ITMX |
| ITRS | International Transactions Reporting System | ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ |



| | | |
|---|---|---|
| KHQR Code | Khmer Quick Response Code | ខេអេចឃ្យូអរកូត |
| KYC | Know Your Customer | នីតិវិធីស្គាល់អតិថិជន |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| NCS | National Clearing System | ប្រព័ន្ធផាត់ទាត់ជាតិ |
| OBS | Online Banking System | ប្រព័ន្ធធនាគារអនឡាញ |
| PFMI | Principles for Financial Market-Infrastructures | គោលការណ៍សម្រាប់-ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ |
| POS | Point of Sale | ម៉ាស៊ីនឆូតកាត |
| QPS | QR Code Payment System | ប្រព័ន្ធទូទាត់តាមឃ្យូអរកូត |
| QR Code | Quick Response Code | ឃ្យូអរកូត |
| RETAIL PAY | Retail Pay System | ប្រព័ន្ធរីថែលផេ |
| RFT | Real-Time Fund Transfer System | ប្រព័ន្ធផ្ទេរប្រាក់ភ្លាមៗ |
| SCB | Siam Commercial Bank | ធនាគារពាណិជ្ជ Siam |
| STP | Straight Through Processing | ប្រតិបត្តិការជាលក្ខណៈស្វ័យប្រវត្តិ |
| SWIFT | The Society for Worldwide Interbank Financial Telecommunication | បណ្តាញទូរគមនាគមន៍ហិរញ្ញវត្ថុនៃធនាគារទូទាំងពិភពលោក |



# បរិយាយសង្ខេប

ស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ ប្រព័ន្ធទូទាត់សងប្រាក់បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាប្រក្រតីភាពនៃសកម្មភាពទូទាត់នៅក្នុងសេដ្ឋកិច្ច និងរួមចំណែកគាំទ្រការកើនឡើងនៃការប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិក (E-commerce) ក៏ដូចជាការប្រែក្លាយសេដ្ឋកិច្ច និងសង្គមឌីជីថលប្រកបដោយភាពរឹងមាំនៅប្រទេសកម្ពុជា។ ដោយមើលឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការនិងបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ទៅតាមដំណាក់កាល រួមមាន ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធបាគង (BAKONG) ប្រព័ន្ធរីថៃលផេ (Retail Pay) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ក្នុងគោលបំណងពង្រឹងសុវត្ថិភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ និងដើម្បីរក្សាលំនឹងនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា។

ប្រព័ន្ធផាត់ទាត់ជាតិដែលជាប្រព័ន្ធទូទាត់សំខាន់មានលក្ខណៈជាប្រព័ន្ធត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជំនាន់ថ្មី ២.០ ដែលមានលក្ខណៈប្រសើរជាងមុនបានដំណើរការដោយពិលាសក្នុងការផាត់ទាត់ និងទូទាត់ប្រតិបត្តិការតាមរយៈមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក។ ទំហំនៃការទូទាត់មូលប្បទានបត្រនិងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកតាមរយៈប្រព័ន្ធផាត់ទាត់ជាតិបានកើនឡើង ដោយមានចំនួនប្រតិបត្តិការតាមរយៈមូលប្បទានបត្រទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកបានកើនឡើង ក្នុងអត្រា ៥,៩% និង ២,៦% រៀងគ្នា ចំណែកឯចំនួនប្រតិបត្តិការតាមបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក បានកើនឡើង ៩១,៧% និង ២0% រៀងគ្នាធៀបនឹងឆ្នាំ២០២១។ ទន្ទឹមនេះ ទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកតាមរយៈប្រព័ន្ធខេមបូឌានស៊ែស្វីច បានកើនឡើងក្នុងអត្រាប្រមាណ ១៣,១% និង ១៩,០៩%។ ចំណែកឯ ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់ជំនាន់ថ្មី ដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញតម្រូវការទូទាត់ឌីជីថល តាមរយៈទូរស័ព្ទចល័ត ដោយក្នុងនោះចំនួនប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកបានកើនឡើងក្នុងអត្រា ២៥៩% និង ២១០%។ ការណ៍នេះបង្ហាញថា នវានុវត្តន៍ផ្នែកប្រព័ន្ធទូទាត់ស្របពេលជាមួយនឹងបទពិសោធន៍ពីជំងឺកូវីដ-១៩ បានក្លាយជាកត្តាដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់។ បន្ទាប់ពីបានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ខាងលើឃើញថា ការប្រើប្រាស់ប្រាក់រៀលមានការកើនឡើងដែលបង្ហាញពីប្រសិទ្ធភាពនៃការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងការដាក់ចេញគោលនយោបាយផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជា និងការយល់ដឹងអំពីសារៈប្រយោជន៍លើការប្រើប្រាស់រូបិយវត្ថុជាតិរបស់ប្រជាជនកម្ពុជា។



ក្រៅពីការដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដោយធនាគារជាតិនៃកម្ពុជា សេវាទូទាត់សងប្រាក់ផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏មានការរីកចម្រើន និងកំពុងប្រកួតប្រជែងនៅលើទីផ្សារ។ អតិថិជនអាចធ្វើប្រតិបត្តិការទូទាត់សងប្រាក់កាន់តែមានភាពងាយស្រួល រហ័ស និងមានកម្រៃកាន់តែសមរម្យជាងមុន តាមរយៈការទូទាត់និងផ្ទេរប្រាក់តាមមធ្យោបាយអេឡិចត្រូនិក ដូចជា សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត សេវាទូទាត់ចល័ត ដែលរួមមានការទូទាត់តាមយូអរកូតផងដែរ។ លើសពីនេះ ចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ចំនួនគណនីកាបូបអេឡិចត្រូនិក ទំហំប្រតិបត្តិការជាអេឡិចត្រូនិក ជាពិសេសការទូទាត់តាមយូអរកូត មានការកើនឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២១។

ប្រព័ន្ធបាគងត្រូវបានបន្តអភិវឌ្ឍសម្រាប់ការផ្ទេរប្រាក់និងទូទាត់ឆ្លងដែន ដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែនជាមួយប្រទេសថៃ និងម៉ាឡេស៊ី និងកំពុងបន្តកិច្ចសហប្រតិបត្តិការនេះជាមួយប្រទេសវៀតណាម និងឡាវ។ កិច្ចសហការនេះនឹងផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ដូចជា ភ្ញៀវទេសចរ និងពលកររវាងប្រទេសដៃគូអាចធ្វើការទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែនបានដោយងាយស្រួល សុវត្ថិភាព និងតម្លៃសមរម្យតាមប្រព័ន្ធទូទាត់ និងផ្ទេរប្រាក់ផ្លូវការ។ ម្យ៉ាងទៀត ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានមួយចំនួនក៏បានដាក់ឱ្យប្រើប្រាស់សេវាផ្ទេរប្រាក់ និងទូទាត់ឆ្លងដែនតាមរយៈមធ្យោបាយឌីជីថល បន្ថែមពីលើការផ្តល់សេវាតាមភ្នាក់ងារនិងបញ្ជរ។

ក្នុងគោលបំណងជំរុញ និងលើកកម្ពស់ការប្រើប្រាស់សេវាទូទាត់ឌីជីថលឱ្យកាន់តែប្រសើរ ប្រព័ន្ធបាគងត្រូវបានប្រើប្រាស់ជាមជ្ឈមណ្ឌលទូទាត់សម្រាប់សម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានតាមរយៈខេអេចយូអរកូត។ លើសពីនេះ ប្រព័ន្ធបាគងបានដើរតួនាទីជាផ្លែតហ្វមធនាគារបើកចំហសម្រាប់មុខងារផ្ទៀងផ្ទាត់គណនីអ្នកទទួលផល ដែលជាថ្នាលចែករំលែកទិន្នន័យអត្តសញ្ញាណសាធារណជនជាមួយប្រព័ន្ធបាគង សម្រាប់យកមកផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនឌីជីថលក្នុងវិស័យធនាគារ និងជាផ្លែតហ្វមបង្ហាញព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីផ្តល់ភាពងាយស្រួលទៅដល់ប្រជាពលរដ្ឋទូទាំងប្រទេស ស្វែងរកមើលព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ជាមួយគ្នានេះដែរ ដើម្បីសម្រួលការទូទាត់អន្តរធនាគារតម្លៃធំ ប្រតិបត្តិការទូទាត់សមតុល្យសុទ្ធរបស់ប្រព័ន្ធទូទាត់រាយ និងប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធបាគងតម្លៃធំព្រមទាំងរៀបចំឯកសារគតិយុត្តស្តីពីវិធាននិងនីតិវិធី ដើម្បីគាំទ្រដំណើរការប្រព័ន្ធនេះផងដែរ។

ដើម្បីលើកកម្ពស់អន្តរប្រតិបត្តិការ និងសុវត្ថិភាពក្នុងការទូទាត់ក្នុងប្រទេសនិងក្នុងតំបន់ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ស្តង់ដារឧបករណ៍ និងតាមបណ្តាញទូទាត់សងប្រាក់ រួមមាន ស្តង់ដារលេខអត្តសញ្ញាណធនាគារ មូលប្បទានបត្រស្តង់ដារ គំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានជាអេឡិចត្រូនិក ដើម្បីសម្រួលដល់ការផាត់ទាត់ និងទូទាត់នៅសភាផាត់ទាត់ជាតិ។ បន្ថែមពីនេះ



ធនាគារជាតិនៃកម្ពុជាក៏បានកំណត់ស្តង់ដារលេខអត្តសញ្ញាណធនាគារលើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក (៩១១៦) និងកំពុងជំរុញគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យប្រើប្រាស់ស្តង់ដារ EMV Chip សម្រាប់ប័ណ្ណទូទាត់។ គោលការណ៍សុវត្ថិភាពនៅលើម៉ាស៊ីន ATM និង/ឬ POS ក៏ត្រូវបានដាក់ឱ្យសមាជិកប្រព័ន្ធខេមបូខានស៊ើស្វីចប្រើប្រាស់ផងដែរ។ ថ្មីៗនេះ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុនិងតម្រូវការទីផ្សារលើសេវានិងឧបករណ៍ទូទាត់ថ្មីៗ ស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់ក៏ត្រូវបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ដូចមានចែងក្នុងប្រកាសស្តីពី គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូតសម្រាប់ការទូទាត់សងប្រាក់ កាលពីថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០២០។

ក្នុងគោលបំណងធានានិរន្តរភាព និងស្ថិរភាពនៃកិច្ចដំណើរការប្រព័ន្ធ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមបទដ្ឋានស្តង់ដារគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់ផ្តោតសំខាន់លើប្រសិទ្ធភាព និងសុវត្ថិភាពនៃប្រតិបត្តិការប្រព័ន្ធទូទាត់ ដោយរួមមានទាំងការតាមដាននិន្នាការនៃប្រតិបត្តិការទូទាត់ និងការគ្រប់គ្រងហានិភ័យ ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យទូទាត់ និងជាពិសេសហានិភ័យដួលរលំជាប្រព័ន្ធ។ ចំណែកឯ ការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដោយយកចិត្តទុកដាក់លើការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសការវាយតម្លៃផ្អែកលើបទប្បញ្ញត្តិប្រុងប្រយ័ត្ន និងច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ក្នុងនាមជាធនាគារកណ្តាល ធនាគារជាតិនៃកម្ពុជាបានដើរតួជានិយ័តករយ៉ាងសំខាន់ ក្នុងការរក្សាតុល្យភាពរវាងគុណសម្បត្តិនៃបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់បរិយាបន្នហិរញ្ញវត្ថុ និងផលប៉ះពាល់សេដ្ឋកិច្ចដែលបច្ចេកវិទ្យាអាចបង្កឡើង។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍នៃបច្ចេកវិទ្យា និងកំណើននៃការប្រើប្រាស់សេវាទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញបទប្បញ្ញត្តិមួយចំនួន និងកំពុងបន្តរៀបចំប្រកាស និងសេចក្តីណែនាំថ្មីៗបន្ថែមទៀតដើម្បីគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ ព្រមទាំងការផ្តល់សេវានិងឧបករណ៍ទូទាត់សងប្រាក់។ ថ្មីៗនេះ សេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិក្នុងដំណាក់កាលសាកល្បង" ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីឱ្យការអនុវត្តមានលក្ខណៈស្តង់ដារ។ ប្រកាសដែលបាននិងកំពុងរៀបចំបន្ថែមទៀតរួមមាន ការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការកំណត់ពីលក្ខខណ្ឌនិងនីតិវិធីសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្នើសុំការអនុញ្ញាតជ្រើសរើសភ្នាក់ងារ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល នីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងប្រកាសដែលកំណត់អំពីនីតិវិធីគ្រប់គ្រងប្រតិបត្តិការ និងប្រតិបត្តិករទីផ្សារឥណទានតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា។



ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលមានសារៈសំខាន់ណាស់សម្រាប់ការអប់រំនៅក្នុងយុគសម័យឌីជីថល។ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានាដើម្បីអនុវត្តការងារអាទិភាពនេះ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ និងបានផ្សព្វផ្សាយអំពីប្រព័ន្ធបាគងទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិស្សានុសិស្ស និងរៀបចំស្តង់ផ្សព្វផ្សាយជាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុកាន់តែទូលំទូលាយ។ ការអនុវត្តនេះនឹងធ្វើឱ្យសាធារណជនប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ជៀសវាងការឆបោក ការក្លែងបន្លំ ការប្រើប្រាស់ទិន្នន័យដោយគ្មានការអនុញ្ញាត និងការទទួលបានសេវាដោយមិនស្មើភាពគ្នាជាដើម។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយធនាគារពិភពលោក រៀបចំសិក្ខាសាលាស្តីពី ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថលជូនដល់មន្ត្រីធនាគារជាតិនៃកម្ពុជាលើប្រធានបទចម្បងៗចំនួន ៣ រួមមាន (១) បទប្បញ្ញត្តិគាំទ្រសម្រាប់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល (២) វិធានការផ្នែកផ្គត់ផ្គង់ដើម្បីជំរុញចំណេះដឹងហិរញ្ញវត្ថុឌីជីថល និង (៣) វិធានការពង្រឹងសមត្ថភាពហិរញ្ញវត្ថុឌីជីថលនៅកម្ពុជា។



# ស្ថិតិអំពីស្ថានភាពសេវាទូទាត់សងប្រាក់

## ១. ស្ថិតិទូទៅ

| | ឆ្នាំ២០២១ | ឆ្នាំ២០២២ (តួលេខប៉ាន់ស្មាន) |
|---|---|---|
| ចំនួនប្រជាជនសរុប (ខ្ទង់លាន) [១] | ១៦,៥៩ | ១៦,៧៧ |
| ផ.ផ.ស សរុប (ខ្ទង់លានដុល្លារអាមេរិក) [២] | ២៦.៩៨៦ | ២៩.៨១២ |
| ផ.ផ.ស ក្នុងប្រជាជនម្នាក់ [២] | ១.៦២៥ | ១.៦៨៩ |
| ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័ត (ខ្ទង់លាន) [៣] | ១៩,៩ | ២០ |
| ចំនួនអ្នកប្រើប្រាស់សេវាអ៊ីនធឺណិត (ខ្ទង់លាន) [៣] | ១៧,៩ | ១៨,០១ |

## ២. គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់៖

| ប្រភេទគ្រឹះស្ថាន | ឆ្នាំ២០២១ | ឆ្នាំ២០២២ | និន្នាការ |
|---|---|---|---|
| ធនាគារពាណិជ្ជ | ៥៥ | ៥៩ | ៧,២៧% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៥ | ៥ | - |
| គ្រឹះ.ផ្តល់សេវាទូទាត់សងប្រាក់ | ៣០ | ៣៥ | ១៦,៦៧% |
| អ្នកដំណើរការតតិយភាគី | ៤ | ៦ | ៥០% |

## ៣. ឧបករណ៍ទូទាត់សងប្រាក់៖ (ឯកតាខ្ទង់លាន)

| ប្រភេទឧបករណ៍ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | និន្នាការ |
|---|---|---|---|
| **៣.១ ប្រភេទឧបករណ៍រូបវន្ត** | | | |
| ប័ណ្ណ Proprietary | ២,៧ | ៣,១ | ១៣% |
| ប័ណ្ណ Debit | ២ | ២,៣ | ១៥% |
| ប័ណ្ណ Credit | ០,១៥ | ០,១៦ | ៧,៥% |
| ប័ណ្ណ Prepaid | ៥,៧ | ៦,៧ | ១៩% |
| **៣.២ ប្រភេទឧបករណ៍បែបឌីជីថល** | | | |
| គណនីកាបូបអេឡិចត្រូនិក | ១៣,៦ | ១៩,៥ | ៤២,៩% |
| គណនីបាគង | ០,២៩ | ០,៥២ | ៧៩,៣១% |

## ៤. បណ្តាញទូទាត់៖ (ឯកតាខ្ទង់ពាន់)

| ចំនួនបណ្តាញទូទាត់ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | និន្នាការ |
|---|---|---|---|
| សាខាធនាគារពាណិជ្ជ | ១,៤៥ | ១,៥០ | ៣,៤៥% |
| សាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ០,៦២ | ០,៦៣ | ១,៦១% |
| ម៉ាស៊ីន ATM | ៣,៦ | ៤,៤ | ២០,៦% |
| ម៉ាស៊ីន POS | ៤៩,៤ | ៥៤,១ | ៩,៤% |
| ភ្នាក់ងារផ្តល់សេវាទូទាត់ | ៤៦,៣ | ៥២,៣ | ១២,៩% |

## ៥. អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់៖ (ឯកតាខ្ទង់លាន)

| ចំនួនអ្នកប្រើប្រាស់ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | និន្នាការ |
|---|---|---|---|
| គណនីធនាគារសន្សំ | ១២,៧ | ១៥,៥ | ២២,០៥% |
| គណនីកាបូបអេឡិចត្រូនិក | ១៣,៦ | ១៩,៥ | ៤២,៩% |
| គណនីបាគង | ០,២៩ | ០,៥២ | ៧៩,៣១% |

[១] ប្រភព៖ ធនាគារពិភពលោក

[២] ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣] ប្រភព៖ និយ័តករទូរគមនាគមន៍កម្ពុជា

## ៦. ប្រតិបត្តិការទូទាត់សងប្រាក់៖ (ឯកតាខ្ទង់លាន)

| | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | និន្នាការ | |
|---|---|---|---|---|---|---|
| | រៀល | ដុល្លារ | រៀល | ដុល្លារ | រៀល | ដុល្លារ |
| **៦.១ មូលប្បទានបត្រ** | | | | | | |
| ចំនួនប្រតិបត្តិការ | ០,០៣២ | ១,០៨ | ០,០៣៤ | ១,១១ | ៦,២៥% | ២,៧៨% |
| ទំហំប្រាក់ | ១៩.០៨៩.៣៥០ | ៤៦.៣៨០ | ១៩.៨៣១.៣១០ | ៥៣.៨៥៤ | ៣,៨៩% | ១៦,១១% |
| **៦.២ បញ្ជាទូទាត់អេឡិចត្រូនិក** | | | | | | |
| ចំនួនប្រតិបត្តិការ | ០,០១៦ | ០,៥៦ | ០,០២៣ | ០,៦៨ | ៤៣,៧៥% | ១៤,២៩% |
| ទំហំប្រាក់ | ៤.៨៩៧.៤៦០ | ១០.៤០៦ | ៤.៥៦១.០១០ | ១២.៣១៩ | (៦,៨៧)% | ១៨,៣៨% |
| **៦.៣ ប័ណ្ណទូទាត់ [៥]** | | | | | | |
| ចំនួនប្រតិបត្តិការ | | ១០៥,៣ | | ១១៩,៧៥ | | ១៣,៧២% |
| ទំហំប្រាក់ | ១២.៨២៩.២៤០ | ១៧.៥៣០ | ២២.៣៦៨.៤៧០ | ១៨.៥១០ | ៧៤,៣៦% | ៣,៨១% |
| **៦.៤ កាបូបអេឡិចត្រូនិក** | | | | | | |
| ចំនួនប្រតិបត្តិការ | ១៤៤,៧៩ | ១៩៩ | ១៩៨,៨ | ២៦៨,៥៧ | ៣៧,៣០% | ៣៤,៩៦% |
| ទំហំប្រាក់ | ៨៨.៤៧៤.២៤០ | ២៦.៩៤០ | ១១៩.៨៩៤.៨៥០ | ៣៤.៣០០ | ៣៥,៥១% | ២៧,៣២% |
| **៦.៥ សេវាធនាគារចល័ត** | | | | | | |
| ចំនួនប្រតិបត្តិការ | ១២,២ | ២៤១,៩ | ៣២,៥៦ | ៤៥២,៥៨ | ១៦៦,៨៩% | ៨៧,០៩% |
| ទំហំប្រាក់ | ២១.២៨៨.៥៩០ | ១០៦.១២០ | ៤៣.៦៣៧.៦៨០ | ១៥៣.៨៣០ | ១០៤,៩៨% | ៤៤,៩៦% |
| **៦.៦ សេវាធនាគារអ៊ីនធឺណិត** | | | | | | |
| ចំនួនប្រតិបត្តិការ | ០,៦៤ | ៣,៧៤ | ០,២៥ | ៣,០៥ | (៦០,៩៤)% | (១៨,៤៥)% |
| ទំហំប្រាក់ | ១៤.៧១៨.៥៥០ | ១៨.៥២០ | ១១.៣១២.៥៨០ | ១៦.៨៣០ | (២៣,១៤)% | (៩,១៣)% |
| **៦.៧ ប្រព័ន្ធបាគង** | | | | | | |
| ចំនួនប្រតិបត្តិការ | ១,៦៤ | ៦,៥៣ | ៥,៨៩ | ២០,២៣ | ២៥៩,១៥% | ២១០,២៨% |
| ទំហំប្រាក់ | ២.៥១៤.៨៧៩ | ២.៨៩២ | ១២.៨១៣.៦៤៧ | ១២.២១១ | ៤០៩,៥១% | ៣២២,២៣% |

[៥] ប្រតិបត្តិការប័ណ្ណទូទាត់ រួមបញ្ចូលប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកជាមួយគ្នា

# ១ វឌ្ឍនភាពរបស់ ប្រព័ន្ធទូទាត់សងប្រាក់

នាយុគសម័យបច្ចេកវិទ្យាបាននិងកំពុងវិវត្តន៍យ៉ាងឆាប់រហ័សជុំវិញពិភពលោក ប្រទេសកម្ពុជាបាននិងកំពុងខិតខំអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនឱ្យប្រែក្លាយទៅជាសេដ្ឋកិច្ចឌីជីថលតាមរយៈការទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធជាតិដែលមានប្រសិទ្ធភាពនិងសុវត្ថិភាព។ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ចទូទាំងសកលលោក រួមទាំងប្រទេសកម្ពុជាផងដែរ។ ស្របពេលជាមួយនឹងការរីករាលដាលនេះ ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ដើម្បីរក្សាលំនឹងនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេស ដោយបានដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ និងកំពុងបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ថ្មីៗបន្ថែមទៀតដើម្បីសម្រួលដល់ការប្រើប្រាស់របស់សាធារណជន ក៏ដូចជាការចូលរួមចំណែកក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់មួយចំនួនរួមមាន ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធបាគង (BAKONG) ប្រព័ន្ធរីថែលផេ (RETAIL PAY) និងប្រព័ន្ធខេមបូឌាន-ស៊ែស្វីច (CSS)។

## ១.១. ការអភិវឌ្ឍចម្បងៗ

ប្រព័ន្ធផាត់ទាត់ជាតិដែលជាប្រព័ន្ធទូទាត់សំខាន់មានលក្ខណៈជាប្រព័ន្ធបានដំណើរការដោយពិលាសក្នុងការផាត់ទាត់ និងទូទាត់ប្រតិបត្តិការមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក។ គួរកត់សម្គាល់ថា ទំហំនៃការទូទាត់មូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកតាមរយៈប្រព័ន្ធផាត់ទាត់ជាតិមាននិន្នាការកើនឡើង ដែលទាំងនេះជាលទ្ធផលនៃការអនុវត្តគោលនយោបាយស្តីពី សមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ ដែលធនាគារជាតិនៃកម្ពុជាបានដាក់ចេញដោយកំណត់លក្ខខណ្ឌក្នុងការចូលរួមជាសមាជិកប្រព័ន្ធផាត់ទាត់ជាតិឡើងវិញ ស្របពេលនឹងការអនុវត្តគោលនយោបាយផ្សេងៗទៀត ដើម្បីលើកកម្ពស់ការទូទាត់ឌីជីថលដូចជា ការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ថ្មីៗបន្ថែមទៀត ដើម្បីផ្តល់ជម្រើសដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការទូទាត់ជាអេឡិចត្រូនិកជាដើម។ ដោយឡែក ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោង អភិវឌ្ឍឡើងដោយប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន (Blockchain) ឬ Distributed Ledger Technology (DLT) ដែលចំនួននិងទំហំប្រាក់នៃប្រតិបត្តិការបន្តកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសប្រតិបត្តិការជាប្រាក់រៀល។



ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយ បច្ចេកវិទ្យាហិរញ្ញវត្ថុបាននិងកំពុងបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការអភិវឌ្ឍលើគ្រប់វិស័យឱ្យកាន់តែប្រសើរឡើងទូទាំងសកលលោក។ នៅប្រទេសកម្ពុជា វត្តមាននៃបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗដូចជា រូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល បានជំរុញឱ្យគ្រឹះស្ថានធនាគារបង្កើនការវិនិយោគលើសេវាធនាគារឌីជីថល ដើម្បីឱ្យដំណើរការទូទាត់កាន់តែពិលាស។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ជាច្រើន ចាប់ផ្តើមផ្តល់សេវាធនាគារឌីជីថល និងសេវាទូទាត់ចល័តដូចជា ផ្តល់ឧបករណ៍ទូទាត់អេឡិចត្រូនិក សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត។ នវានុវត្តន៍ផ្នែកប្រព័ន្ធទូទាត់ស្របពេលជាមួយនឹងបទពិសោធន៍ពីជំងឺកូវីដ-១៩ បានក្លាយជាកត្តាដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់។ ជាមួយគ្នានោះ កំណើននៃតម្រូវការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ច និងនវានុវត្តន៍ផ្នែកប្រព័ន្ធទូទាត់ ជាពិសេសប្រព័ន្ធបាគងក៏បានធ្វើឱ្យការទូទាត់អេឡិចត្រូនិកជាប្រាក់រៀលមាននិន្នាការកើនឡើងជាបន្តបន្ទាប់បើធៀបនឹងឆ្នាំកន្លងទៅ។

**ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរណ៍ និងទំហំប្រាក់ទូទាត់តាមអេឡិចត្រូនិកជាប្រាក់រៀល**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រៅពីវឌ្ឍនភាពដ៏ឆាប់រហ័សនេះ ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ បានជំរុញឱ្យមានការប្រើប្រាស់ការទូទាត់សងប្រាក់តាមរយៈការស្កេនឃ្យូអរកូត (QR Code) ដែលជាមធ្យោបាយទូទាត់ពេញនិយមនាពេលបច្ចុប្បន្ន ជាពិសេសប្រជាជនមានវ័យជំទង់ដែលអាចសម្របខ្លួនក្នុងការទទួលយកបច្ចេកវិទ្យាថ្មីៗ។ ដោយមើលឃើញការដាក់ឱ្យប្រើប្រាស់ការទូទាត់សងប្រាក់តាមរយៈ



ការស្កេន QR Code របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មិនទាន់មានលក្ខណៈស្តង់ដាររួមមួយ ដែលធ្វើឱ្យអតិថិជនមិនអាចធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានបាន ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមធនាគារនៅកម្ពុជា និងភាគីពាក់ព័ន្ធបានរៀបចំ និងដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ ដែលជាស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់នៅកម្ពុជាស្របតាមស្តង់ដារអន្តរជាតិ EMV។ ការដាក់ឱ្យប្រើប្រាស់ស្តង់ដារ QR Code បានរួមចំណែកលើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់តាម QR Code ព្រមទាំងផ្តល់លទ្ធភាពសម្រាប់ប្រទេសកម្ពុជាក្នុងការធ្វើសមាហរណកម្មការទូទាត់ក្នុងតំបន់អាស៊ាន ដែលការទូទាត់តាម QR Code នេះក៏បានក្លាយជាការងារអាទិភាពមួយនៅក្នុងក្របខណ្ឌនៃការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់ផងដែរ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនៃការភ្ជាប់ការទូទាត់តាម QR Code រវាងប្រទេសកម្ពុជា និងប្រទេសថៃ និងកំពុងបន្តអនុវត្តការងារនេះជាមួយប្រទេសផ្សេងៗទៀតក្នុងតំបន់អាស៊ានរួមមាន ប្រទេសវៀតណាម និងប្រទេសឡាវ។ ក្រាហ្វខាងក្រោមបង្ហាញថា ចំនួននិងទំហំប្រាក់នៃប្រតិបត្តិការទូទាត់តាម QR Code កំពុងបន្តកើនឡើងគួរឱ្យកត់សម្គាល់ បើទោះបីជាទំហំប្រាក់នៃការទូទាត់តាម QR Code នៅមានកម្រិតធៀបនឹងការទូទាត់តាមប័ណ្ណទូទាត់ក៏ដោយ។

**ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈការស្កេន QR Code និងប័ណ្ណទូទាត់**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



## ១.២. គោលនយោបាយគាំទ្រ

ប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពមានសារៈសំខាន់ណាស់ ចំពោះដំណើរការប្រកបដោយប្រសិទ្ធភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចទាំងមូល។ ប្រព័ន្ធទូទាត់សងប្រាក់ដែលមានដំណើរការល្អជួយពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ កាត់បន្ថយការចំណាយនៅក្នុងសេដ្ឋកិច្ច បង្កើននូវប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងបង្កើនសន្ទនីយភាពក្នុងទីផ្សារហិរញ្ញវត្ថុ។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់សងប្រាក់មួយចំនួន ក្នុងគោលបំណងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអ្នកប្រើប្រាស់មានលទ្ធភាពធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានទូលំទូលាយ។ ទោះជាយ៉ាងណា ការអនុវត្តគោលនយោបាយនិងលក្ខណៈបច្ចេកទេសរបស់ប្រព័ន្ធមួយចំនួន ជាកត្តារួមចំណែកបង្កការលំបាកសម្រាប់គ្រឹះស្ថាននិងអតិថិជនក្នុងការប្រើប្រាស់ផងដែរ។ ជាក់ស្តែង ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន បង្កើនសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងធានាប្រសិទ្ធភាពក្នុងការធ្វើប្រតិបត្តិការបានប្រសើរជាងមុន។ ប្រព័ន្ធផាត់ទាត់ជាតិជំនាន់ថ្មីនេះត្រូវបានធ្វើបច្ចុប្បន្នកម្ម ដោយភ្ជាប់មកជាមួយនឹងយន្តការ Failure Tolerance Mechanism ដែលមានបង្ហាញ Notification នៅពេលដែលប្រព័ន្ធមានបញ្ហាផ្នែកណាមួយ (System Failure) ឬ មានភាពមិនប្រក្រតីដែលទាមទារឱ្យធ្វើ Recovery។ លើសពីនេះ ប្រព័ន្ធផាត់ទាត់ជាតិនេះក៏បានរៀបចំ Design ជា Interface ថ្មីដែលមានលក្ខណៈបច្ចេកទេសទំនើបជាងមុន និងងាយស្រួលក្នុងការធ្វើប្រតិបត្តិការ និងបានអភិវឌ្ឍនូវមុខងារថ្មីមួយបន្ថែមទៀតគឺ មុខងារ Straight through processing (STP) ដែលសម្រួលដល់ការធ្វើប្រតិបត្តិការរបស់ប្រព័ន្ធផាត់ទាត់ជាតិលើការផ្តល់សេវាផាត់ទាត់មូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកឱ្យកាន់តែមានភាពងាយស្រួល និងប្រសិទ្ធភាព។

ទន្ទឹមនេះ ប្រព័ន្ធសេវាទូទាត់រហ័សដែលធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការកាលពីឆ្នាំ២០១៦ ជាប្រព័ន្ធទូទាត់មួយដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ឆ្លងគ្រឹះស្ថានបាន ប៉ុន្តែប្រតិបត្តិការអាចធ្វើឡើងបានតែប្រាក់រៀលប៉ុណ្ណោះ និងមិនទាន់មានមុខងារផ្ទៀងផ្ទាត់ព័ត៌មានអ្នកទទួលផល (Recipient Account Inquiry) នៅឡើយ។ ដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័សកាន់តែមានភាពងាយស្រួល និងប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើទំនើបកម្មប្រព័ន្ធសេវាទូទាត់រហ័សទៅជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី ដោយដាក់ឱ្យប្រើប្រាស់មុខងារថ្មីៗបន្ថែមទៀតតាមដំណាក់កាល។ ដំណាក់កាលទី១ ជាការធ្វើទំនើបកម្មប្រព័ន្ធផ្ទៃក្នុងរបស់គ្រឹះស្ថានសមាជិក (Upgrading the Client Module System) និងការផ្លាស់ប្តូរការតភ្ជាប់មកកាន់ប្រព័ន្ធទូទាត់រហ័សជំនាន់ថ្មី និងដំណាក់កាលទី២ គឺការធ្វើសន្ទានកម្មលើមុខងារថ្មីទាំងបី ដែលរួមមាន ១/.មុខងារផ្ទៀងផ្ទាត់ព័ត៌មានអ្នកទទួលផល (Recipient Account Inquiry) ២/.ផាត់ទាត់និងទូទាត់ប្រតិបត្តិការជារូបិយប័ណ្ណដុល្លារអាមេរិក (US Dollar Transaction) និង ៣/.ការធ្វើប្រតិបត្តិការជាលក្ខណៈស្វ័យប្រវត្តិពេញលេញ



(Full Straight Through Processing – STP)។ ធនាគារជាតិនៃកម្ពុជារំពឹងទុកថា បន្ទាប់ពីគ្រឹះស្ថានសមាជិកទាំងអស់បញ្ចប់ការធ្វើទំនើបកម្មប្រព័ន្ធលើគ្រប់មុខងារនឹងធ្វើឱ្យការប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័សកាន់តែមានភាពងាយស្រួលសម្រាប់អតិថិជន ហើយចំនួនប្រតិបត្តិការនឹងបន្តកើនឡើងបន្ថែមទៀត។

ចំពោះការទូទាត់តាមប័ណ្ណទូទាត់នៅប្រទេសកម្ពុជា អតិថិជននៅតែពេញនិយមក្នុងការប្រើប្រាស់ប័ណ្ណទូទាត់ដើម្បីធ្វើការទូទាត់ទំនិញ និងប្រតិបត្តិការដក/ដាក់ប្រាក់តាមម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ជាពិសេសការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធ។ ក្នុងគោលបំណងសម្រួលដល់ការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការបឋមប្រព័ន្ធខេមបូឌានស៊ែស្វិច (CSS) កាលពីខែតុលា ឆ្នាំ២០១៧ ដែលអនុញ្ញាតឱ្យអ្នកកាន់ប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុកមានលទ្ធភាពប្រើប្រាស់ប័ណ្ណទូទាត់របស់ខ្លួនលើគ្រប់ម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិក។ ការដាក់ឱ្យដំណើរការប្រព័ន្ធនេះនឹងក្លាយជាកត្តាមួយជំរុញការទូទាត់រាយជាអេឡិចត្រូនិក កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ បង្កើនប្រសិទ្ធភាពប្រព័ន្ធទូទាត់តាមរយៈការកាត់បន្ថយការវិនិយោគលើម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ លើកកម្ពស់អន្តរប្រតិបត្តិការ និងផ្តល់ភាពងាយស្រួលក្នុងការទូទាត់ទំនិញ និងសេវា។ ទោះបីជាយ៉ាងណា ការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយផងដែរ។ ជាក់ស្តែង ប័ណ្ណទូទាត់ឥណពន្ធដែលប្រើប្រាស់បច្ចេកវិទ្យា Magnetic stripe ចេញផ្សាយដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្រុក នៅមិនទាន់ឆ្លើយតបទៅនឹងស្តង់ដារសុវត្ថិភាពទាំងស្រុងនៅឡើយ ដោយសារប្រព័ន្ធសុវត្ថិភាពរបស់បច្ចេកវិទ្យានេះនៅមានកម្រិតទាប ដែលអាចបង្កឱ្យមានការលួចបន្លំផ្សេងៗក្នុងការធ្វើប្រតិបត្តិការរបស់អតិថិជន។ ដើម្បីលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធនៅប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានដាក់ចេញសេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយប្រព័ន្ធខេមបូឌានស៊ែស្វិច ក្នុងគោលបំណងជំរុញគ្រឹះស្ថានសមាជិកប្រើប្រាស់ស្តង់ដារលេខ CSS-BIN និងប្រើប្រាស់ស្តង់ដារ EMV Chip សម្រាប់ប័ណ្ណទូទាត់ក្នុងស្រុកជំនួសបច្ចេកវិទ្យា Magnetic stripe វិញ ការផ្តល់ជម្រើសសម្រាប់ការទទួលយកនិងចេញផ្សាយប័ណ្ណទូទាត់រួមស្លាកសញ្ញារវាងប្រព័ន្ធខេមបូឌានស៊ែស្វិច និងក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ និងការពង្រឹងសុវត្ថិភាពលើម៉ាស៊ីន ATM និង POS។

ទន្ទឹមនោះ ការវិវត្តន៍យ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុបានធ្វើឱ្យកំណើននៃការប្រើប្រាស់សេវាទូទាត់ និងឧបករណ៍ទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ ជាពិសេសការផ្លាស់ប្តូរបរិបទនៃការផ្តល់សេវាហិរញ្ញវត្ថុ និងការដាក់ឱ្យដំណើរការសេវាទូទាត់ និងឧបករណ៍ទូទាត់ដែលប្រកបដោយនវានុវត្តន៍។ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងនោះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាស និងគោលការណ៍ណែនាំមួយចំនួនរួចមក ហើយដូចជា គោលការណ៍គ្រប់គ្រងហានិភ័យព័ត៌មានវិទ្យាសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ



និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អនុវត្តដើម្បីពង្រឹងប្រព័ន្ធសុវត្ថិភាពផ្ទៃក្នុង ក្នុងការផ្តល់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាព និងកំពុងបន្តរៀបចំប្រកាស និងសេចក្តីណែនាំថ្មីៗបន្ថែមទៀតដើម្បីគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ ព្រមទាំងការផ្តល់សេវានិងឧបករណ៍ទូទាត់សងប្រាក់។

ស្ថិតក្នុងបរិបទនៃការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) បានផ្តល់ឱកាសឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ទុះស្ទារប្រកួតប្រជែងទាក់ទាញអតិថិជន តាមរយៈការដាក់ឱ្យប្រើប្រាស់នូវសេវានិងឧបករណ៍ទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍មានដូចជា សេវាធនាគារតាមអ៊ីនធឺណិត ឬសេវាធនាគារចល័ត (Internet Banking/Mobile Banking) សេវាទូទាត់ចល័ត (Mobile Payment) ប័ណ្ណទូទាត់ និងការទូទាត់តាម QR Code។ ការទូទាត់តាម QR Code ជាមធ្យោបាយទូទាត់ថ្មីមួយ ដែលទើបតែលេចឡើងនៅលើទីផ្សារ ប៉ុន្តែការទូទាត់តាម QR Code កំពុងបន្តកើនឡើង និងទទួលបាននូវការពេញនិយមគួរឱ្យកត់សម្គាល់ក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសក្នុងស្រទាប់យុវវ័យ ដែលអាចសម្របខ្លួនក្នុងការទទួលយកនូវបច្ចេកវិទ្យាថ្មីៗ ព្រោះការទូទាត់តាម QR Code មានភាពងាយស្រួលរហ័ស និងមានសុវត្ថិភាព ជាពិសេសក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ បានក្លាយជាកត្តាដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់។ ទោះបីជាការទូទាត់តាម QR Code ផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនក៏ដោយក៏នៅមានបញ្ហាប្រឈមជាសារវន្តដែលទាមទារឱ្យមានការយកចិត្តទុកដាក់ ដោយសារបច្ចុប្បន្នគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បានដាក់ឱ្យដំណើរការការទូទាត់តាមយូអរកូត (QR Code Payment) នៅតាមហាងលក់ទំនិញរបស់ពាណិជ្ជករទូទាត់រាយ ប៉ុន្តែ QR Code ទាំងនោះពុំទាន់មានលក្ខណៈស្តង់ដាររួមគ្នាអាចធ្វើប្រតិបត្តិការទូទាត់ឆ្លងប្រព័ន្ធគ្នាបាននៅឡើយ។ កត្តានេះពុំមានលក្ខណៈស្របតាមឧត្តមានុវត្តន៍ និងបង្កភាពបន្ទប់បង្អាក់ដល់នវានុវត្តន៍ក្នុងទីផ្សារ ជាពិសេសអតិថិជនងាយទទួលរងការក្លែងបន្លំក្នុងការធ្វើប្រតិបត្តិការទូទាត់។ ដោយពិនិត្យឃើញនូវបញ្ហាប្រឈមនេះ និងភាពចាំបាច់ត្រូវដោះស្រាយដើម្បីបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពនៃការទូទាត់តាម QR Code ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការខេអេចយូអរកូត (KHQR Code) កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ ដែលជាសមិទ្ធផលថ្មីមួយ និងក្លាយជាចលករក្នុងការពន្លឿន និងលើកកម្ពស់ការទូទាត់តាម KHQR Code ឱ្យមានសណ្តាប់ធ្នាប់ ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព កាត់បន្ថយចំណាយប្រតិបត្តិការ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ។

តាមការអនុវត្តកន្លងមក ធនាគារជាតិនៃកម្ពុជាបានរៀបចំសេចក្តីណែនាំ ព្រមទាំងវិធាននិងនីតិវិធីសម្រាប់ជាចំណងផ្លូវច្បាប់គ្រប់គ្រងលើការអនុវត្ត និងប្រតិបត្តិការរបស់ប្រព័ន្ធនីមួយៗ ដោយផ្តោតសំខាន់លើសមាជិកភាពរបស់ប្រព័ន្ធ តួនាទីនិងការទទួលខុសត្រូវ លំហូរប្រតិបត្តិការ ប្រភេទរូបិយប័ណ្ណ ពេលវេលាផាត់ទាត់និងទូទាត់ កម្រៃ សោហ៊ុយនិងការពិន័យ និងដំណោះស្រាយវិវាទជាដើម។ ផ្អែកលើគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាស្តង់ដារ

អន្តរជាតិសម្រាប់វាយតម្លៃប្រព័ន្ធទូទាត់បានបង្ហាញឱ្យឃើញថា ហានិភ័យប្រតិបត្តិការជាហានិភ័យសំខាន់មួយដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការប្រព័ន្ធទូទាត់ ហើយក្នុងករណីធ្ងន់ធ្ងរ អាចបង្កឱ្យមានហានិភ័យជាប្រព័ន្ធថែមទៀតដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ។ ម្យ៉ាងទៀត ផ្អែកលើឧត្តមានុវត្តន៍ជាសកល ហានិភ័យប្រតិបត្តិការទាមទារឱ្យមានយន្តការច្បាស់លាស់ក្នុងការគ្រប់គ្រងនិងដោះស្រាយ ពីព្រោះហានិភ័យប្រតិបត្តិការអាចកើតមានឡើងច្រើនទម្រង់ និងទាមទារឱ្យមានដំណោះស្រាយផ្សេងៗគ្នា។ វិធាននិងនីតិវិធីរបស់ប្រព័ន្ធនីមួយៗក៏បានគ្របដណ្តប់លើយន្តការមួយចំនួនក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការផងដែរ។ ទោះជាយ៉ាងណា យន្តការទាំងនោះនៅមិនទាន់គ្រប់គ្រាន់សម្រាប់គ្រប់គ្រងហានិភ័យប្រតិបត្តិការតាមទម្រង់ផ្សេងៗដែលអាចកើតមានឡើងស្របតាមស្តង់ដារអន្តរជាតិនិងឧត្តមានុវត្តន៍ឡើយ។ ហេតុដូចនេះ ក្នុងគោលដៅរក្សាបាននូវសន្តតិភាពក្នុងការប្រើប្រាស់ប្រព័ន្ធ ធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរនិងប្រតិបត្តិករប្រព័ន្ធទូទាត់ បាននិងកំពុងរៀបចំផែនការនិរន្តរភាពសម្រាប់ប្រព័ន្ធទូទាត់ដែលជាឯកសាររៀបរាប់លម្អិតអំពីយន្តការគ្រប់គ្រងហានិភ័យប្រតិបត្តិការទៅតាមហេតុការណ៍នីមួយៗដូចជា ផែនការសង្គ្រោះគ្រោះមហន្តរាយ នីតិវិធីក្នុងការទាញយកទិន្នន័យមកវិញ ពេលវេលានៃដំណើរការឡើងវិញ កិច្ចសហការរវាងដៃគូពាក់ព័ន្ធ និងយន្តការផ្សេងៗដែលតម្រូវឱ្យមានការធ្វើតេស្តជាប្រចាំ។

បន្ទាប់ពីបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ និងក្របខណ្ឌបទប្បញ្ញត្តិរួចមក កត្តាសំខាន់ដែលមិនអាចខ្វះបានមួយទៀតគឺ ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថលដល់សាធារណជន។ កន្លងមកថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាសហការជាមួយធនាគារពិភពលោកបានរៀបចំសិក្ខាសាលាស្តីពី ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល ជូនដល់មន្ត្រីធនាគារជាតិនៃកម្ពុជារយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ លើប្រធានបទចម្បងៗចំនួនបី រួមមាន (១) បទប្បញ្ញត្តិគាំទ្រសម្រាប់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល (២) វិធានការផ្អែកផ្គត់ផ្គង់ដើម្បីជំរុញចំណេះដឹងហិរញ្ញវត្ថុឌីជីថល និង (៣) វិធានការពង្រឹងសមត្ថភាពហិរញ្ញវត្ថុឌីជីថលនៅកម្ពុជា។ ក្នុងគោលបំណងផ្តល់ឱកាសដល់មន្ត្រីពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ពិភាក្សា ចែករំលែកចំណេះដឹង និងសិក្សាបន្ថែមពីគោលនយោបាយ និងការអនុវត្តប្រកបដោយឧត្តមានុវត្តន៍ពីវាគ្មិនពាក់ព័ន្ធនឹងចំណេះដឹងហិរញ្ញវត្ថុឌីជីថល។ ក្រោយពីបញ្ចប់សិក្ខាសាលានេះ ធនាគារពិភពលោកគ្រោងនឹងរៀបចំក្របខណ្ឌស្តីពី ហិរញ្ញវត្ថុឌីជីថល ដើម្បីផ្តល់ជាគំនិតផ្តួចផ្តើមសំខាន់ៗក្នុងការចែករំលែកចំណេះដឹងហិរញ្ញវត្ថុឌីជីថលឱ្យកាន់តែសម្បូរបែប ក៏ដូចជាពង្រឹងបន្ថែមនូវកម្មវិធីសិក្សាដែលមានស្រាប់ដែលអាចរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលឱ្យកាន់តែប្រសើរឡើង។





ធនាគារជាតិនៃកម្ពុជាសហការជាមួយធនាគារពិភពលោក
បានរៀបចំសិក្ខាសាលាស្ដីពី ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល ជូនមន្ត្រីធនាគារជាតិនៃកម្ពុជា
កាលពីថ្ងៃទី២១ ដល់ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

## ១.៣. ជំហានបន្ទាប់

ដើម្បីសម្រេចបាននូវគោលដៅនៃការអនុវត្តគោលនយោបាយដូចបានរៀបរាប់ខាងលើ ការផ្ដល់ការគាំទ្រនិងកិច្ចសហការដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកប្រព័ន្ធ និងភាគីពាក់ព័ន្ធគឺជាកត្តាចាំបាច់។ ក្រុមការងារអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិ និងប្រព័ន្ធសេវាទូទាត់រហ័សរបស់ធនាគារជាតិនៃកម្ពុជានៅតែបន្តផ្ដល់កិច្ចសហការ ការណែនាំ និងគាំទ្រយ៉ាងពេញលេញដល់គ្រឹះស្ថានជាសមាជិកទាំងអស់ ដើម្បីជំរុញឱ្យគ្រឹះស្ថានជាសមាជិកទាំងនោះមានលទ្ធភាពក្នុងការធ្វើទំនើបកម្មប្រព័ន្ធផាត់ទាត់ជាតិ និងប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មីបានដោយជោគជ័យតាមដំណាក់កាលនីមួយៗ។

ម្យ៉ាងទៀត ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការអនុលោមតាមសេចក្ដីជូនដំណឹងស្ដីពីគោលនយោបាយប្រព័ន្ធខេមបូឌានស៊ើស្វីច ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានវឌ្ឍនភាព និងសហការជាមួយគ្រឹះស្ថានសមាជិក និងភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហានានាដែលកើតមានឡើង ដើម្បីអាចឱ្យការអនុវត្តគោលនយោបាយ ដែលមានចែងក្នុងសេចក្ដីជូនដំណឹងសម្រេចបានតាមគោលដៅ។

ធនាគារជាតិនៃកម្ពុជាក៏នឹងបន្តគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការអនុវត្តខេអេច-ឃ្យូអរកូត ដើម្បីឱ្យការអនុវត្តស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់អាចសម្រេចបានទាំងស្រុងក្នុងការត្រៀមខ្លួនសម្រាប់ការធ្វើអន្តរប្រតិបត្តិការទូទាត់តាមរយៈឃ្យូអរកូតទាំងក្នុងប្រទេស និងក្នុងតំបន់។

ទន្ទឹមគ្នានេះដែរ ដោយសារប្រព័ន្ធបាគងមានលក្ខណៈជាហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នងដែលជាឱកាសសម្រាប់អភិវឌ្ឍប្រព័ន្ធដទៃទៀត ហេតុដូចនេះទើបធនាគារជាតិនៃកម្ពុជាបន្តអនុវត្តការងារជាច្រើនទៀត ដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយទាំងក្នុងស្រុក និងតំបន់។

ការវិវត្តន៍ និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ជាពិសេសលើសេវាទូទាត់សងប្រាក់ និងសេវាផ្ទេរប្រាក់ បានអភិវឌ្ឍយ៉ាងឆាប់រហ័ស ដែលការណ៍នេះបានផ្តល់ឱកាសសម្រាប់ធនាគារជាតិនៃកម្ពុជាដែលជានិយ័តករ បន្តសិក្សា និងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសមស្របថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងនោះ។

បន្ថែមលើនេះ ដើម្បីជំរុញការប្រើប្រាស់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាពនិងនិរន្តរភាព ការបង្កើនការយល់ដឹងដល់សាធារណជនអំពីរបៀបប្រើប្រាស់ឱ្យបានទូលំទូលាយ គឺជាកត្តាចាំបាច់ និងទាមទារឱ្យមានការរៀបចំជាក្របខណ្ឌ និងផែនការសកម្មភាពផ្សេងៗក្រោមកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តផែនការលើកកម្ពស់ចំណេះដឹងឌីជីថលទទួលបានប្រសិទ្ធភាពខ្ពស់។



## ប្រអប់ ១ - ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

ក្នុងយុគសម័យសកលភាវូបនីយកម្ម ដែលមានបដិវត្តន៍ឧស្សាហកម្ម ៤.០ ជានិន្នាការដឹកមុខ បច្ចេកវិទ្យាហិរញ្ញវត្ថុបានបោះជំហានយ៉ាងលឿន ហើយបានក្លាយជាចលករសម្រាប់ជំរុញការគ្របដណ្តប់ និងការតភ្ជាប់បណ្តាសេដ្ឋកិច្ចនិងសង្គមនៅទូទាំងពិភពលោកឱ្យកាន់តែមានភាពប្រទាក់ក្រឡាគ្នា និងអាស្រ័យគ្នាទៅវិញទៅមក។

ធនាគារជាតិនៃកម្ពុជាបានអនុម័តផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់វិស័យធនាគារ កាលពីឆ្នាំ២០២០ កន្លងទៅ ដោយផ្តោតលើសសរស្តម្ភចំនួន ៣ រួមមាន (១) សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ (២) បច្ចេកវិទ្យាគាំទ្រ និង (៣) គោលនយោបាយជំរុញ។ ផែនទីមគ្គុទ្ទេសក៍នេះមានទស្សនៈវិស័យក្នុងការបណ្តុះបរិវត្តកម្មឌីជីថលនៅក្នុងវិស័យធនាគារ ដោយផ្តោតលើការងារមួយចំនួនពាក់ព័ន្ធនឹងការដាក់ចេញនូវគោលនយោបាយ បទប្បញ្ញត្តិ សម្រួលដល់ការផ្តល់សេវានិងផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាគំរូធុរកិច្ចថ្មីស្របតាមនវានុវត្តន៍ ព្រមទាំងជំរុញការប្រើប្រាស់ឱ្យមានភាពទូលំទូលាយផងដែរ។

ទន្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុថ្នាក់ជាតិ ដោយធ្វើការកំណត់ផែនការសកម្មភាព និងយុទ្ធសាស្ត្រឆ្លើយតបនានា ដើម្បីជំរុញបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារឱ្យមានសន្ទុះទៅមុខ។ ធនាគារជាតិនៃកម្ពុជាសហការជាមួយគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល បានរៀបចំសេចក្តីព្រាងគោលនយោបាយ និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីស្ថានភាព និងកាលានុវត្តភាពនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលយកមកកសាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យបានគ្រប់ជ្រុងជ្រោយ។



# ២ នវានុវត្តន៍ប្រព័ន្ធបាគង

ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាហិរញ្ញវត្ថុ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោង អភិវឌ្ឍឡើងដើម្បីសម្រួលដល់ការធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថាន បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់សងប្រាក់ លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសម្រួលប្រតិបត្តិការទូទាត់ជាប្រាក់រៀល។ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបាគង បានផ្តល់ជាអត្ថប្រយោជន៍បន្ថែមដល់សាធារណជន អាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់តាមឃ្យូអរកូតឆ្លងគ្រឹះស្ថាន និងទូទាត់ឆ្លងដែនចំណាយប្រតិបត្តិការទាប និងមានសុវត្ថិភាព។ សមាជិកភាពប្រព័ន្ធបាគងមានដូចជា ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ គិតត្រឹមដំណាច់ឆ្នាំ២០២២ ប្រព័ន្ធបាគងមានសមាជិកសរុបចំនួន ៦៩ គ្រឹះស្ថាន ដោយក្នុងនោះមានគ្រឹះស្ថានចំនួន ៤៦ បានដាក់ឱ្យដំណើរការជាផ្លូវការ និងគ្រឹះស្ថានចំនួន ២៣ ទៀតបាននិងកំពុងបន្តធ្វើសន្ធានកម្មប្រព័ន្ធ។




## ២.១. វឌ្ឍនភាព

### ២.១.១. ចំនួនអតិថិជនប្រើប្រាស់ប្រព័ន្ធបាគង

គិតត្រឹមដំណាច់ឆ្នាំ២០២២ អតិថិជនចុះឈ្មោះប្រើប្រាស់បាគងតាមរយៈកម្មវិធីបាគងមានចំនួន ៥២២,៦ ពាន់គណនី កើនឡើង ៨១,៨% បើធៀបនឹងឆ្នាំ២០២១ មាន ២៨៧,៥ ពាន់គណនី។

**ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់ជាមួយកម្មវិធីបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.១.២. ប្រតិបត្តិការប្រព័ន្ធបាគង

ក្នុងឆ្នាំ២០២២ ប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់ដែលធ្វើឡើងតាមរយៈប្រព័ន្ធបាគងមានចំនួន ២៦,១២ លានប្រតិបត្តិការ ក្នុងនោះ ៥,៨៩ លានប្រតិបត្តិការ ជាប្រាក់រៀល និង ២០,២៣ លានប្រតិបត្តិការ ជាប្រាក់ដុល្លារអាមេរិក និងមានទំហំប្រាក់ជាប្រាក់រៀលចំនួន ១២,៨១ ទ្រីលានរៀល និងជាប្រាក់ដុល្លារអាមេរិកចំនួន ១២,២១ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៥២% នៃផ.ស.ស។ បន្ទាប់ពីដាក់ដំណើរការប្រព័ន្ធបាគង យើងសង្កេតឃើញថា ការប្រើប្រាស់ប្រាក់រៀលមានការកើនឡើងជាងមុនការដាក់ឱ្យដំណើរការប្រព័ន្ធបាគង ដូចបានបង្ហាញក្នុងក្រាហ្វខាងក្រោម៖

**ក្រាហ្វ ៤ - ប្រតិបត្តិការធ្វើឡើងតាមរយៈប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មុនដាក់និងបន្ទាប់ពីបានដាក់ដំណើរការប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.២. សមិទ្ធផល

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តការងារជាច្រើនទៀតដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធបាគងឱ្យកាន់តែមានភាពងាយស្រួល សុវត្ថិភាព និងកាន់តែទូលំទូលាយ។ សមិទ្ធផលចម្បងៗនៃការពង្រីកបន្ថែមជាមួយប្រព័ន្ធបាគងកន្លងមកមានដូចជា៖

### ២.២.១. ការផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែនតាមប្រព័ន្ធបាគង

ការផ្ទេរប្រាក់និងការទូទាត់ឆ្លងដែនបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងក្នុងពិភពលោកជាពិសេសក្នុងតំបន់អាស៊ាន។ ទន្ទឹមនោះ ការផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែន ក៏បានរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការផ្តល់ជាមធ្យោបាយសម្រួលដល់ការផ្ទេរប្រាក់និងទូទាត់ទំនិញ ដែលមានកម្រៃទាបសម្រាប់ពលករចំណាកស្រុក និងអ្នកធុរកិច្ច។

ក្នុងគោលបំណងពង្រឹងកិច្ចសហការលើការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ និងប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ឆ្លងដែនប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមកិច្ចសហការជាមួយបណ្តាធនាគារកណ្តាលក្នុងតំបន់ និងដៃគូពាក់ព័ន្ធ ដើម្បីរៀបចំ និងសម្របសម្រួលបណ្តាញទូទាត់សងប្រាក់ផ្លូវការដែលមានសុវត្ថិភាព និងប្រសិទ្ធភាព។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់បណ្តាញទូទាត់សងប្រាក់ជាមួយប្រទេសក្នុងតំបន់ដូចមានក្នុងរូបភាពខាងក្រោម៖



ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈយោគយល់លើការតភ្ជាប់បណ្តាញទូទាត់សងប្រាក់ជាមួយប្រទេសថៃ និងប្រទេសម៉ាឡេស៊ី នៅឆ្នាំ២០១៩ និងជាមួយប្រទេសវៀតណាម និងប្រទេសឡាវ នៅចុងឆ្នាំ២០២២។

## ក). គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ បានចុះអនុស្សរណៈយោគយល់គ្នា កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៩ លើកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ ដែលគម្រោងនេះត្រូវបានចាប់ផ្តើមអនុវត្តដោយតភ្ជាប់ការទូទាត់ឆ្លងដែនតាមយ្យូអរកូតជាជំហានដំបូង និងផ្ទេរប្រាក់ឆ្លងដែនជាជំហានបន្ទាប់។

ចំពោះការទូទាត់ឆ្លងដែនតាមយ្យូអរកូត ភាគីទាំងពីរបានឯកភាពអនុវត្តជាដំណាក់កាល ដោយដំណាក់កាលទី១ ផ្តល់លទ្ធភាពទូទាត់ឆ្លងដែនតាមយ្យូអរកូតពីប្រទេសកម្ពុជាទៅប្រទេសថៃ និងដំណាក់កាលទី២ ផ្តល់លទ្ធភាពទូទាត់ឆ្លងដែនតាមយ្យូអរកូតពីប្រទេសថៃមកប្រទេសកម្ពុជា។ ដើម្បីអនុវត្តគម្រោងនេះ ធនាគារជាតិនៃកម្ពុជាបានជ្រើសរើសធនាគារអេស៊ីលីដាភីអិលស៊ី ធនាគារកម្ពុជាពាណិជ្ជ និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ជាធនាគារទំនាក់ទំនង (Sponsoring Bank) ខណៈធនាគារកណ្តាលថៃបានជ្រើសរើសធនាគារ Siam Commercial Bank (SCB) ជាធនាគារទូទាត់ និងក្រុមហ៊ុន ITMX ជាប្រតិបត្តិករប្រព័ន្ធ។ គ្រឹះស្ថានធនាគារដែលមានបំណងដាក់ឱ្យប្រើប្រាស់ការទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជានិងប្រទេសថៃសម្រាប់អតិថិជនរបស់ខ្លួន ត្រូវធ្វើការទំនាក់ទំនងទៅធនាគារទំនាក់ទំនងទាំងបី ដូចបានរៀបរាប់ខាងលើនេះ។ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ធនាគារអេស៊ីលីដាភីអិលស៊ី និងធនាគារកម្ពុជាពាណិជ្ជ បានបញ្ចប់ការអភិវឌ្ឍ និងដាក់ឱ្យដំណើរការទូទាត់ឆ្លងដែនពីប្រទេសកម្ពុជាទៅប្រទេសថៃ ខណៈធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជាបានដាក់ឱ្យដំណើរការបឋមនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។ បច្ចុប្បន្ន អតិថិជនរបស់ធនាគារអេស៊ីលីដាភីអិលស៊ី ធនាគារហត្ថាកសិករ ធនាគារស្ថាបនា និងធនាគារប្រៃសណីយ៍កម្ពុជា អាចធ្វើការទូទាត់

តាមឃ្យូអរកូតនៅតាមបណ្តាពាណិជ្ជករនៅប្រទេសថៃ។ គិតចាប់ពីពេលដាក់ឱ្យដំណើរការរហូតដល់ចុងឆ្នាំ២០២១ និងដើមឆ្នាំ២០២២ ចំនួនប្រតិបត្តិការទូទាត់ពីប្រទេសកម្ពុជាទៅប្រទេសថៃមានការថយចុះ ដោយសារទទួលរងផលប៉ះពាល់ និងឥទ្ធិពលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងការបិទច្រកឆ្លងដែនរវាងប្រទេសទាំងពីរកន្លងមក។ ប៉ុន្តែនៅឆមាសទី២ ឆ្នាំ២០២២ ចំនួនប្រតិបត្តិការចាប់ផ្តើមមានសន្ទុះកើនឡើងវិញ បន្ទាប់ពីភាពធូរស្រាលនៃជំងឺកូវីដ-១៩ និងការបើកច្រកឆ្លងដែនឡើងវិញ។

**តារាង ១ - ប្រតិបត្តិការទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ**

| ឆ្នាំ | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាដុល្លារអាមេរិក) |
|---|---|---|
| ឆ១ - ២០២០ | ១៥១ | ៥.៤១៦,០៦ |
| ឆ២ - ២០២០ | ២៧០ | ៧០.៦៣៥,៦៤ |
| ឆ១ - ២០២១ | ១៦៦ | ៣៦.៩០៨,២០ |
| ឆ២ - ២០២១ | ១៥០ | ១១.១៤៥,២៨ |
| ឆ១ - ២០២២ | ៣៩ | ៣.៩៦៧,៧៣ |
| ឆ២ - ២០២២ | ២.១៧៦ | ១៤៦.២៥៦,៤១ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦ - ប្រតិបត្តិការទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ). គម្រោងទូទាត់ជាមួយប្រទេសម៉ាឡេស៊ី

កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សរណៈយោគយល់គ្នាជាមួយធនាគារមេយប៊ែងនៅកម្ពុជា និងធនាគារមេយប៊ែងម៉ាឡេស៊ី លើកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី ដើម្បីសម្រួលដល់ពលករចំណាកស្រុកអាចប្រើប្រាស់បណ្តាញផ្លូវការតាមរយៈប្រព័ន្ធបាគង និងផ្ទៃតហ្វមឌីជីថលរបស់ធនាគារមេយប៊ែង។



ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់អំពី កិច្ចសហប្រតិបត្តិការក្នុងការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែនតាមរយៈប្រព័ន្ធបាគង
រវាងធនាគារជាតិនៃកម្ពុជាជាមួយធនាគារមេយប៊ែងនៅកម្ពុជា និងធនាគារមេយប៊ែងម៉ាឡេស៊ី
កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា

គម្រោងនេះបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ កន្លងទៅ ដើម្បីសម្រួលដល់ប្រជាជននៃប្រទេសទាំងពីរ ជាពិសេស ពលករចំណាកស្រុកកម្ពុជាដែលកំពុងរស់នៅ និងធ្វើការនៅប្រទេសម៉ាឡេស៊ី និងប្រជាជនម៉ាឡេស៊ីដែលកំពុងរស់នៅប្រទេសកម្ពុជា ក៏ដូចជាអ្នកធុរកិច្ច អាចផ្ទេរមូលនិធិឆ្លងប្រទេសសម្រាប់ទូទាត់ពាណិជ្ជកម្ម និងក្រុមគ្រួសារបានទទួលប្រាក់ផ្ទេរដោយផ្ទាល់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព កម្រៃសមរម្យ និងរហ័ស ដែលសមាជិកគ្រួសារអាចប្រើប្រាស់បន្តសម្រាប់គាំទ្រ និងលើកស្ទួយកម្រិតជីវភាពគ្រួសារបានប្រសើរជាងមុន។ គម្រោងនេះ បានរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រការវិវត្តន៍ឆ្ពោះទៅរកសង្គមឌីជីថលរវាងប្រទេសទាំងពីរ។

ទន្ទឹមនោះ កាលពីខែឧសភា ឆ្នាំ២០២២ ធនាគារកម្ពុជាសាធារណៈ ក៏បានធ្វើសន្ទានកម្មដាក់ឱ្យដំណើរការការផ្ទេរប្រាក់ពីប្រទេសម៉ាឡេស៊ីមកប្រទេសកម្ពុជា តាមបញ្ជរ និងកម្មវិធីធនាគារចល័តរបស់ធនាគារកម្ពុជាសាធារណៈនៃប្រទេសម៉ាឡេស៊ីមកប្រទេសកម្ពុជាតាមរយៈប្រព័ន្ធបាគងផងដែរ។

**តារាង ២ - ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី**

| ឆ្នាំ | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
|---|---|---|
| ឆ២ - ២០២១ | ៨៩៨ | ១,១២ |
| ឆ១ - ២០២២ | ១.៦៦៨ | ៣,៦២ |
| ឆ២ - ២០២២ | ១.៩៣៣ | ៣,៧៩ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧ - ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### គ). គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសវៀតណាម

ធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម បានចុះអនុស្សរណៈយោគយល់គ្នា កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២២ លើកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ ដែលគម្រោងនេះត្រូវបានចាប់ផ្ដើមអនុវត្តដោយតភ្ជាប់ការទូទាត់ឆ្លងដែនតាមយូអរកូត។ ភាគីទាំងពីរបានឯកភាពអនុវត្តជា ២ ដំណាក់កាល ដោយដំណាក់កាលទី១ ផ្ដល់លទ្ធភាពឱ្យអតិថិជនពីប្រទេសកម្ពុជាអាចទៅធ្វើការស្កេនទូទាត់នៅប្រទេសវៀតណាម និងដំណាក់កាលទី២ ផ្ដល់លទ្ធភាពឱ្យអតិថិជនពីប្រទេសវៀតណាមអាចមកស្កេនទូទាត់នៅប្រទេសកម្ពុជា ដែលគ្រោងនឹងបញ្ចប់នៅឆមាសទី១ ឆ្នាំ២០២៣។




ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្ដីពី
កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ រវាងធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម
កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិមានសន្តិភាព រាជធានីភ្នំពេញ

### ឃ). គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសឡាវ

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឡាវ បានចុះអនុស្សរណៈយោគយល់គ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ លើកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ ដែលគម្រោងនេះត្រូវបានចាប់ផ្តើមអនុវត្តដោយតភ្ជាប់ការទូទាត់ឆ្លងដែនតាមឃ្យូអរកូត។ ភាគីទាំងពីរបានឯកភាពអនុវត្តជា ២ ដំណាក់កាល ដោយដំណាក់កាលទី១ ផ្តល់លទ្ធភាពឱ្យអតិថិជនពីប្រទេសកម្ពុជាទៅស្កេនទូទាត់នៅប្រទេសឡាវ និងដំណាក់កាលទី២ ផ្តល់លទ្ធភាពអតិថិជនពីប្រទេសឡាវ មកស្កេនទូទាត់នៅប្រទេសកម្ពុជា ដែលគ្រោងនឹងបញ្ចប់នៅឆមាសទី១ ឆ្នាំ២០២៣។




ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី
កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឡាវ
កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា

### ២.២.២. ប្រព័ន្ធបាគងសម្រាប់ប្រព័ន្ធទូទាត់តម្លៃធំ

បន្ទាប់ពីដាក់ឱ្យដំណើរការប្រព័ន្ធបាគងសម្រាប់ប្រព័ន្ធទូទាត់រាយ ធនាគារជាតិនៃកម្ពុជាបានបន្តសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់តម្លៃធំ។ ការសិក្សាផ្តោតសំខាន់លើបទពិសោធន៍របស់ប្រទេសនានាដែលកំពុងធ្វើតេស្តសាកល្បងលើការប្រើប្រាស់បច្ចេកវិទ្យា DLT សម្រាប់ការទូទាត់តម្លៃធំ ក៏ដូចជាផលប៉ះពាល់លើគោលនយោបាយរូបិយវត្ថុ និងស្ថិរភាពហិរញ្ញវត្ថុ

ព្រមទាំងហានិភ័យផ្សេងៗ។ បច្ចុប្បន្ន មានធនាគារកណ្តាល និងស្ថាប័នពាក់ព័ន្ធជាច្រើនទាំងក្នុងតំបន់ និងពិភពលោក បាននិងកំពុងសិក្សាអំពីអត្ថប្រយោជន៍នៃបច្ចេកវិទ្យា DLT និងធ្វើតេស្តសាកល្បងបច្ចេកវិទ្យានេះក្នុងការគាំទ្រដល់ការទូទាត់តម្លៃធំ និងការទូទាត់ឆ្លងដែនជាដើម។ ទន្ទឹមនោះ កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារធនាគារជាតិនៃកម្ពុជាបានទៅបំពេញទស្សនកិច្ចសិក្សានៅប្រទេសថៃ ដើម្បីសិក្សាពីបទពិសោធន៍របស់ធនាគារកណ្តាលថៃក្នុងការអនុវត្តគម្រោង Inthanon ដែលជាគម្រោងសិក្សាអំពីលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា DLT សម្រាប់ការទូទាត់ដុលក្លាមៗផងដែរ។ ការអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់តម្លៃធំត្រូវបានអនុវត្តជាដំណាក់កាល ដែលក្នុងនោះមុខងារមូលដ្ឋានរបស់ប្រព័ន្ធនឹងត្រូវបានអភិវឌ្ឍក្នុងដំណាក់កាលដំបូង ចំណែកឯមុខងារសំខាន់ៗផ្សេងទៀតនឹងត្រូវអភិវឌ្ឍក្នុងដំណាក់កាលជាបន្តបន្ទាប់។ បច្ចុប្បន្ន ក្រុមការងារធនាគារជាតិនៃកម្ពុជាកំពុងរៀបចំឯកសារគតិយុត្តស្តីពីវិធាននិងនីតិវិធី ដើម្បីគាំទ្រដំណើរការប្រព័ន្ធនេះ។ ការអនុវត្តគម្រោងបាគងសម្រាប់ប្រព័ន្ធទូទាត់តម្លៃធំនឹងរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព និងសុវត្ថិភាពការទូទាត់តម្លៃធំឱ្យកាន់តែប្រសើរឡើង ស្របតាមនិន្នាការនៃការអភិវឌ្ឍប្រព័ន្ធទូទាត់ក្នុងតំបន់ និងសកល។

### ២.២.៣. ការលើកកម្ពស់ការទូទាត់ប្រព័ន្ធបាគងជាមួយវិស័យសាធារណៈ

ដើម្បីគាំទ្រដល់គោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមលើកកម្ពស់ការទូទាត់ឌីជីថលជាមួយវិស័យសាធារណៈ តាមរយៈការពង្រីកមុខងារប្រព័ន្ធបាគងសម្រាប់គាំទ្រដល់ការទូទាត់សេវាសាធារណៈជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ មានដូចជា ក្រសួងមុខងារសាធារណៈ ក្រសួងពាណិជ្ជកម្ម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអគ្គនាយកដ្ឋានពន្ធដារជាដើម ដើម្បីអភិវឌ្ឍលើមុខងារសម្រាប់ទូទាត់បង់ពន្ធដារ បើកប្រាក់បៀវត្សប្រាក់សោធន៍និវត្តន៍ ច្រកទូទាត់ក្នុងផ្សារពាណិជ្ជកម្មអេឡិចត្រូនិក (Cambodia trade) និងច្រកសម្រាប់ផ្តល់មូលនិធិគាំទ្រដល់ជនក្រីក្រ កុមារកំព្រា និងទ្រទ្រង់គ្រោះមហន្តរាយផ្សេងៗ។

### ២.២.៤. ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល និងការផ្សព្វផ្សាយជំរុញការប្រើប្រាស់ប្រព័ន្ធបាគង

ការលើកកម្ពស់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុដែលមានភាពល្អប្រសើរតាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុ ទាមទារនូវការយល់ដឹងផ្នែកហិរញ្ញវត្ថុឌីជីថល ដើម្បីឱ្យសាធារណៈប្រើប្រាស់សេវាទាំងនោះឱ្យមានប្រសិទ្ធភាព និងជៀសវាងការឆបោក ការក្លែងបន្លំ ការប្រើប្រាស់ទិន្នន័យដោយគ្មានការអនុញ្ញាត និងការទទួលបានសេវាដោយមិនស្មើភាពគ្នាជាដើម។ ដូចនេះ ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលមានសារៈសំខាន់កាន់តែខ្លាំងឡើងសម្រាប់ការអប់រំនៅក្នុងយុគសម័យឌីជីថល។

ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលជាការងារអាទិភាពរបស់ធនាគារជាតិនៃកម្ពុជា ដោយសារចំណេះដឹងផ្នែកឌីជីថលជាធាតុសំខាន់មួយក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ និងបរិវត្តកម្ម



ឌីជីថល។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានាដើម្បីអនុវត្តការងារអាទិភាពនេះ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាក៏បានផ្សព្វផ្សាយអំពីប្រព័ន្ធបាគងទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិស្សានុសិស្ស និងរៀបចំស្តង់ផ្សព្វផ្សាយជាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុឌីជីថលឱ្យបានកាន់តែទូលំទូលាយ។



សិក្ខាសាលាស្តីពី ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល និងការផ្សព្វផ្សាយអំពីប្រព័ន្ធបាគង
ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិស្សានុសិស្ស និងការរៀបចំស្តង់ផ្សព្វផ្សាយជាសាធារណៈ

## ប្រអប់ ២ - ការអភិវឌ្ឍមុខងារចុះឈ្មោះអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង

បន្ទាប់ពីធនាគារជាតិនៃកម្ពុជាដាក់ដំណើរការប្រព័ន្ធបាគងប្រកបដោយភាពជោគជ័យ ធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញពីឱកាសក្នុងការបន្តអភិវឌ្ឍប្រព័ន្ធបាគងនៅក្នុងជំហានបន្ទាប់ ដើម្បីឱ្យប្រព័ន្ធបាគងអាចបំពេញមុខងារសម្បូរបែប និងភាពងាយស្រួលសម្រាប់អតិថិជនធ្វើប្រតិបត្តិការទូទាត់ឌីជីថល សំដៅសម្រេចបាននូវប្រតិបត្តិការពេញលេញ។ ដោយសារតែក្នុងការអនុវត្តបច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលចុះឈ្មោះអតិថិជនប្រើប្រាស់ប្រព័ន្ធបាគង បានអនុវត្តនីតិវិធីផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន (KYC) តាមវិធីសាស្ត្រ Manual Approach នៅតាមបញ្ជររបស់គ្រឹះស្ថាន ឬ តាមបែបឌីជីថលទៅតាមវិធានដោយឡែកៗគ្នារបស់គ្រឹះស្ថាននីមួយៗ ដូច្នេះ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ធនាគារជាតិនៃកម្ពុជាបានសិក្សានិងពិនិត្យលទ្ធភាព ប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) របស់មជ្ឈមណ្ឌលបណ្តុះធុរៈកិច្ចថ្មី "តេជោ" សម្រាប់យកមកផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាឌីជីថល នៅពេលអតិថិជនចុះឈ្មោះបើកគណនីប្រើប្រាស់ប្រព័ន្ធបាគង។

ជាលទ្ធផល ធនាគារជាតិនៃកម្ពុជា និងមជ្ឈមណ្ឌលបណ្តុះធុរៈកិច្ចថ្មី "តេជោ" នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល ដើម្បីគាំទ្រដល់នីតិវិធីចុះឈ្មោះអតិថិជនជាឌីជីថល ព្រមទាំងបង្កើនប្រសិទ្ធភាពក្នុងការផ្ទៀងផ្ទាត់ឱ្យកាន់តែមានសង្គតិភាព រហ័ស និងជួយសម្រួលដល់ការចុះឈ្មោះអតិថិជនក្នុងការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុប្រកបដោយជំនឿទុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងសំដៅគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។



## ប្រអប់ ៣ - ការអភិវឌ្ឍមុខងារបង្ហាញព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងប្រព័ន្ធបាគង

ដើម្បីផ្ដល់ភាពងាយស្រួលទៅដល់ប្រជាពលរដ្ឋទូទាំងប្រទេស ស្វែងរកមើលព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ និងដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស បានរៀបចំឱ្យមានក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ តាមរយៈការចុះអនុស្សរណៈយោគយល់ស្ដីពី "កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់តំណភ្ជាប់សម្រាប់ស្វែងរកមើលព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩របស់សាមីបុគ្គលតាមរយៈប្រព័ន្ធបាគង" កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។ អនុស្សរណៈយោគយល់នេះរៀបចំឡើង ក្នុងគោលបំណងពង្រីកវិសាលភាពនៃការទទួលបាននូវព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ របស់បុគ្គល តាមរយៈការប្រើប្រាស់ប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា ជាមួយតំណភ្ជាប់ប្រព័ន្ធកត់ត្រាចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួងសុខាភិបាល។ គំនិតផ្ដួចផ្ដើមនេះ នឹងរួមចំណែកជំរុញការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍ថ្មីៗ ព្រមទាំងសម្រួលដល់ប្រជាពលរដ្ឋអាចទទួលបានភាពងាយស្រួលជាងមុន ក្នុងករណីភ្លេចយកប័ណ្ណចាក់វ៉ាក់សាំងមកតាមខ្លួន ពួកគាត់អាចប្រើប្រាស់ប្រព័ន្ធបាគង ដើម្បីស្វែងរកព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ របស់ខ្លួនបានយ៉ាងងាយស្រួលផងដែរ។ បច្ចុប្បន្ន ក្រុមការងារបច្ចេកទេសកំពុងធ្វើសន្ទានកម្មជាមួយប្រព័ន្ធបាគង ព្រមទាំងរំពឹងទុកជាមុនថានឹងដាក់ឱ្យដំណើរការក្នុងពេលឆាប់ៗនេះ។



## ប្រអប់ ៤ - ការអភិវឌ្ឍស្តង់ដារខេអេចឃ្យូអរកូត ( KHQR Code )

ស្ថិតក្នុងបរិបទនៃការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) បានផ្តល់ឱកាសឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកួតប្រជែងទាក់ទាញអតិថិជន តាមរយៈការដាក់ឱ្យប្រើប្រាស់សេវា និងឧបករណ៍ទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍។ ការទូទាត់តាមឃ្យូអរកូត (QR Code) ជាមធ្យោបាយទូទាត់ថ្មីមួយ ដែលទើបតែលេចឡើងនៅលើទីផ្សារ ប៉ុន្តែការទូទាត់តាម QR Code កំពុងបន្តកើនឡើងនិងទទួលបានការពេញនិយមគួរឱ្យកត់សម្គាល់ក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសក្នុងស្រទាប់យុវវ័យ ដែលអាចសម្របខ្លួនក្នុងការទទួលយកនូវបច្ចេកវិទ្យាថ្មីៗ ព្រោះការទូទាត់តាម QR Code មានភាពងាយស្រួល រហ័ស និងសុវត្ថិភាព ជាពិសេសក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ បានក្លាយជាកត្តាដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់ និងបានរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ២០១៩-២០២៥ និងតម្រង់ទិសឆ្ពោះទៅរកគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាល ២០២១-២០៣៥។

ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមរៀបចំកសាង អភិវឌ្ឍ QR Code ស្តង់ដារ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ KHQR Code នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ ដើម្បីជួយលើកកម្ពស់ការទូទាត់តាម QR Code ឱ្យមានសណ្តាប់ធ្នាប់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព កាត់បន្ថយចំណាយប្រតិបត្តិការ និងបរិយាបន្ន។ គិតចាប់ពីថ្ងៃដាក់ឱ្យដំណើរការរហូតដល់ដំណាច់ឆ្នាំ២០២២ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤៦ បានបង្ហាញនូវឆន្ទៈមោះមុតក្នុងការអភិវឌ្ឍនិងបានដាក់ដំណើរការនៅតាមហាងលក់ទំនិញរបស់ពាណិជ្ជករប្រមាណ ២៣០.០០០ ទីតាំង។



# ៣ ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់

ទន្ទឹមនឹងការជំរុញនវានុវត្តន៍ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាតួនាទីចម្បងមួយ ផងដែររបស់ធនាគារជាតិនៃកម្ពុជា ក្នុងចំណោមតួនាទីផ្សេងៗទៀត។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ អនុវត្តឡើងក្នុងគោលបំណងរក្សាសុវត្ថិភាពនិងប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងមូល និងដើម្បីធានាថាប្រព័ន្ធទាំងនោះគោរពតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។

ទន្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលជាឯកសារមូលដ្ឋានបង្ហាញពីគោលដៅនៃគោលនយោបាយត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលអនុវត្តដោយធនាគារជាតិនៃកម្ពុជា ហើយក៏ជាគោលការណ៍ណែនាំសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃពីកម្រិតហានិភ័យចម្បងៗក្នុងប្រព័ន្ធទូទាត់សងប្រាក់។

## ៣.១. ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់

### ៣.១.១. ប្រព័ន្ធផាត់ទាត់ជាតិ (NCS)

ប្រព័ន្ធផាត់ទាត់ជាតិ បានរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រួលដល់ការផាត់ទាត់ និងទូទាត់ជាលក្ខណៈមជ្ឈការលើប្រតិបត្តិការអន្តរធនាគារ តាមរយៈឧបករណ៍ទូទាត់សងប្រាក់ជាមូលប្បទានបត្រ និងបញ្ជាផ្ទេរឥណទានទាំងជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក រវាងគ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធផាត់ទាត់ជាតិប្រកបដោយប្រសិទ្ធភាពនិងភាពងាយស្រួល។ ប្រព័ន្ធផាត់ទាត់ជាតិមានគ្រឹះស្ថានជាសមាជិកចំនួន ៥៦ ដែលក្នុងនោះគ្រឹះស្ថានចំនួន ៤១ ជាសមាជិកផ្ទាល់ និង ១៥ គ្រឹះស្ថានជាសមាជិកមិនផ្ទាល់។

#### ក). មូលប្បទានបត្រ

គិតត្រឹមឆ្នាំ២០២២ ចំនួនមូលប្បទានបត្រជាប្រាក់រៀលដែលបានឆ្លងកាត់ការផាត់ទាត់ និងទូទាត់តាមរយៈប្រព័ន្ធផាត់ទាត់ជាតិមាន ៣៣.៦០៨ សន្លឹក (កើន ៥,៩%) និងទំហំប្រាក់ ១៩.៨៣១,៣១ ប៊ីលានរៀល (កើនឡើង ៣,៩%)។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់រៀលមាន ៦៨ សន្លឹក (ថយចុះ ៣១,៣%) និងទំហំប្រាក់ ៨៨,៩១ ប៊ីលានរៀល (ថយចុះ ៨១%)។



ស្របគ្នានេះដែរ ចំនួនមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកក៏មាន ១.១០៥.៧១២ សន្លឹក (កើនឡើង ២,៦%) និងទំហំប្រាក់ ៥៣.៨៥៣,៩៤ លានដុល្លារអាមេរិក (កើនឡើង ១៦,១%)។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់ដុល្លារអាមេរិកមាន ៨.៧៣៩ សន្លឹក (កើនឡើង ៣,៨%) និងទំហំប្រាក់ ១.៧៦៣,៩៦ លានដុល្លារអាមេរិក (កើនឡើង ២៤០,៦%)។ ទំហំប្រាក់សរុបមូលប្បទានបត្រធ្វើប្រតិបត្តិការតាមប្រព័ន្ធផាត់ទាត់ជាតិមានទំហំប្រមាណ ១៩៨% នៃផ.ស.ស។

**តារាង ៣ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់រៀល**

| ឆ្នាំ | មូលប្បទានបត្រ ជាប្រាក់រៀល | | មូលប្បទានបត្របង្វិលវិញ ជាប្រាក់រៀល | |
|---|---|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) |
| ឆ២ - ២០១៩ | ២១.៨៧០ | ៧.០៨៧,០២ | ១១៣ | ១២៤,៦៧ |
| ឆ១ - ២០២០ | ១៧.៩៦៦ | ១៤.០២៧,៧៥ | ៥៩ | ៤.៥៥៣,២៩ |
| ឆ២ - ២០២០ | ១៧.៦០៤ | ៨.៩២៧,៥៧ | ៤២ | ៥២១,៦៣ |
| ឆ១ - ២០២១ | ១៥.៦៧៣ | ៩.៦២១,៩១ | ៤៤ | ៤១៦,៨៣ |
| ឆ២ - ២០២១ | ១៦.០៧៦ | ៩.៤៦៧,៤៦ | ៥៥ | ៤៩,៦០ |
| ឆ១ - ២០២២ | ១៦.៦៣៤ | ៩.៧៣៦,៦៩ | ៣៧ | ៧៣,១៦ |
| ឆ២ - ២០២២ | ១៦.៩៧៤ | ១០.០៩៤,៦២ | ៣១ | ១៥,៧៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**តារាង ៤ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក**

| ឆ្នាំ | មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក | | មូលប្បទានបត្របង្វិលវិញ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) | ចំនួន | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៦៩២.៧៨៥ | ២៦.៧៦៧,៩៥ | ៥.៤៩៤ | ៣.៤០៩,៨៥ |
| ឆ១ - ២០២០ | ៦០៧.៥១០ | ២៩.១៩៤,៤៥ | ៤.៥៧៤ | ៨.៣៤០,៤២ |
| ឆ២ - ២០២០ | ៥៩២.៦០០ | ២១.០៧៨,៥៩ | ៤.០៤៦ | ៣៩៧,៣៧ |
| ឆ១ - ២០២១ | ៥២០.៩២៦ | ២១.៨០១,០២ | ៣.៩៥៤ | ២២៣,២៦ |
| ឆ២ - ២០២១ | ៥៥៦.១៧៩ | ២៤.៥៨០,១៥ | ៤.៤៦៩ | ២៩៤,៦៣ |
| ឆ១ - ២០២២ | ៥៥១.៧៩៣ | ២៧.១៩២,១០ | ៤.០២៩ | ៣៥២,០១ |
| ឆ២ - ២០២២ | ៥៥៣.៩១៩ | ២៦.៦៦១,៨៤ | ៤.៧១០ | ១.៤១១,៩៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា



**ក្រាហ្វ ៨ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

យោងតាមក្រាហ្វខាងលើ បង្ហាញថា ឧបករណ៍មូលប្បទានបត្រដែលធ្វើប្រតិបត្តិការផាត់ទាត់ និងទូទាត់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិទាំងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកមានការកើនឡើង ទាំងទំហំប្រាក់និងចំនួនប្រតិបត្តិការ ដែលបង្ហាញថាមូលប្បទានបត្រនៅតែជាឧបករណ៍ទូទាត់សងប្រាក់ដែលពេញនិយមប្រើប្រាស់សម្រាប់ការទូទាត់ក្នុងសេដ្ឋកិច្ច។

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជានៅតែបន្តអនុវត្តវិធានការមួយចំនួន ដើម្បីកាត់បន្ថយការប្រើប្រាស់មូលប្បទានបត្រ តាមរយៈការលើកទឹកចិត្តឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក និងបន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកពង្រឹងការអនុវត្តលក្ខខណ្ឌទាក់ទងនឹងការប្រើប្រាស់មូលប្បទានបត្រ តាមដានសមតុល្យគណនីជាប្រចាំ និងសិក្សាពីវិធានការនានា ដើម្បីទប់ស្កាត់និងកាត់បន្ថយឱ្យបានជាអតិបរមានូវចំនួនមូលប្បទានបត្របង្វិលវិញ។

ទន្ទឹមនោះ ក្នុងគោលបំណងឱ្យការប្រើប្រាស់មូលប្បទានបត្រប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយហានិភ័យក្នុងប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យគ្រឹះស្ថានកត់ត្រាព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលបានចេញផ្សាយមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ចូលប្រព័ន្ធចែករំលែកព័ត៌មានឥណទាន យោងតាមប្រកាសលេខ ធ៧.០២០.៣៥២ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ស្ដីពី ការចែករំលែកព័ត៌មានឥណទាន។

## ខ). បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក

ក្នុងរយៈពេលដូចគ្នានេះ ចំនួនប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលមាន ២២.៥៤០ ប្រតិបត្តិការ (កើនឡើង ៩១,៧%) ដែលមានទំហំប្រាក់ ៤.៥៦១ ប៊ីលានរៀល (ថយចុះ ៦,៩%)។ ជាមួយគ្នានេះ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកមានចំនួន ៦៧៥.៤៥១ ប្រតិបត្តិការ (កើនឡើង ២០%) ស្របគ្នានឹងការកើនឡើងនូវទំហំប្រាក់ដែលមាន ១២.៣១៩,៣១ លានដុល្លារអាមេរិក (កើនឡើង ១៨,៤%)។ ទំហំប្រាក់សរុបបញ្ជាផ្ទេរឥណទានធ្វើប្រតិបត្តិការតាមប្រព័ន្ធផាត់ទាត់ជាតិមានទំហំប្រមាណ ៤៥% នៃផ.ស.ស។

**តារាង ៥ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធផាត់ទាត់ជាតិ**

| ឆ្នាំ | បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល | | បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) | ចំនួន | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៣.៧២៩ | ២.៣៣២,៣២ | ១២៣.០៤៥ | ៤.០៣០,០៩ |
| ឆ១ - ២០២០ | ៤.៣៤២ | ២.៣៤០,៨៥ | ១៤០.១២២ | ៤.០៤៩,៥៨ |
| ឆ២ - ២០២០ | ៥.៧៥៩ | ២.៣២២,៤០ | ១៨៨.៣១២ | ៨.៦៥៧,០១ |
| ឆ១ - ២០២១ | ៦.៨៥៥ | ២.៥២១,៨០ | ២៦០.៤២៣ | ៤.៨៩២,២៥ |
| ឆ២ - ២០២១ | ៩.០៤៣ | ២.៣៨៥,៦៦ | ៣០២.៦៥៤ | ៥.៥១៣,៨៨ |
| ឆ១ - ២០២២ | ១០.០២៨ | ២.៦២៣,៩២ | ៣២០.៣៣០ | ៦.៣៣៩,៧២ |
| ឆ២ - ២០២២ | ១២.៥១២ | ១.៩៣៧,០៩ | ៣៥៥.១២១ | ៥.៩៧៩,៥៩ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០២២ នេះ ចំនួនបញ្ជាផ្ទេរជាប្រាក់រៀលមានការកើនឡើង ប៉ុន្តែទំហំប្រាក់មានការថយចុះបន្តិច បើធៀបនឹងឆ្នាំ២០២១។ ដោយឡែក ចំពោះបញ្ជាផ្ទេរជាប្រាក់ដុល្លារអាមេរិក មានការកើនឡើងទាំងចំនួន និងទំហំប្រាក់។ ជាលទ្ធផលបង្ហាញថា សាធារណជនមានការយល់ដឹង និងបានប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិកកាន់តែច្រើនជាងមុន។ ដើម្បីបន្តជំរុញការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជាបាននិងកំពុងដាក់ចេញគោលការណ៍មួយចំនួនដូចជាពង្រីកបណ្តាញផ្តល់សេវាបញ្ជាផ្ទេរប្រាក់តាមរយៈសេវាធនាគារអ៊ីនធឺណិត ឬសេវាធនាគារចល័ត ដើម្បីបង្កើនភាពងាយស្រួលសម្រាប់អតិថិជនប្រើប្រាស់ និងលើកទឹកចិត្តក្នុងការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិក តាមរយៈការយកកម្រៃប្រតិបត្តិការតិចជាងប្រតិបត្តិការមូលប្បទានបត្រ។



ក្រាហ្វ ៩ - បញ្ញាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣.១.២. ប្រព័ន្ធសេវាទូទាត់រហ័ស (FAST)

ដើម្បីសម្រួលដល់ការធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគារជាប្រាក់រៀល និងសម្រួលឱ្យអតិថិជនអាចទទួលបានមូលនិធិភ្លាមៗ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័សកាលពីឆ្នាំ២០១៦ និងត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី (FAST 2.0) ដែលបានដាក់ឱ្យដំណើរការ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ កន្លងទៅ ដោយមានបន្ថែមមុខងារ និងលក្ខណៈពិសេសមួយចំនួន ក្នុងការសម្រួលដល់ការធ្វើប្រតិបត្តិការប្រព័ន្ធសេវាទូទាត់រហ័សឱ្យកាន់តែប្រសើរជាងមុន។ ក្នុងឆ្នាំ២០២២ នេះ គ្រឹះស្ថានសមាជិកដែលកំពុងដំណើរការផ្លូវការប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មីមានចំនួន ៥៦ គ្រឹះស្ថាន ដែលក្នុងនោះមានសមាជិកជាគ្រឹះស្ថានធនាគារពាណិជ្ជចំនួន ៥២ និងសមាជិកជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៤។

ក្នុងរយៈពេលដូចគ្នានេះ បញ្ញាផ្ទេរឥណទានតាមប្រព័ន្ធសេវាទូទាត់រហ័សមាន ២២.៧៣៣ ប្រតិបត្តិការ (ថយចុះ ៦៣,៣%) និងទំហំប្រាក់មានចំនួន ៧១,៧៧ ប៊ីលានរៀល (ថយចុះ ៥0%)។ ទំហំប្រាក់សរុបរបស់សេវាទូទាត់រហ័សធ្វើប្រតិបត្តិការតាមប្រព័ន្ធផាត់ទាត់ជាតិមានទំហំប្រមាណ 0,0៦% នៃផ.ស.ស។



តារាង ៦ - បញ្ញាផ្ញើរឥណទានតាមប្រព័ន្ធ FAST

| ឆ្នាំ | បញ្ញាផ្ញើរឥណទាន ជាប្រាក់រៀល តាមប្រព័ន្ធ FAST | |
|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) |
| ឆ២ - ២០១៩ | ១១.៥៤៨ | ១០០,២ |
| ឆ១ - ២០២០ | ២១.៣៦៣ | ៩៥,២៥ |
| ឆ២ - ២០២០ | ២៥.៥៧១ | ៨៩,៧៤ |
| ឆ១ - ២០២១ | ៣៩.៩២៥ | ៩៧,០០ |
| ឆ២ - ២០២១ | ២២.០៩៩ | ៤៦,១៨ |
| ឆ១ - ២០២២ | ៦.៥២៦ | ២៩,៣១ |
| ឆ២ - ២០២២ | ១៦.២០៧ | ៤២,៤៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ១០ - បញ្ញាផ្ញើរឥណទាន តាមប្រព័ន្ធ FAST




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ផ្អែកតាមទិន្នន័យខាងលើបង្ហាញថា ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការដែលធ្វើឡើងតាមរយៈប្រព័ន្ធសេវាទូទាត់រហ័សមានការថយចុះ ដោយសារការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធសេវាទូទាត់រហ័ស ហើយសមាជិកដែលបានដំណើរការជាផ្លូវការប្រព័ន្ធនេះឡើងវិញ នៅមានចំនួនតិចតួចនៅឡើយ។

ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធនេះឱ្យបានកាន់តែមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបាននិងកំពុងជំរុញគ្រឹះស្ថានជាសមាជិកឱ្យពង្រីកបណ្តាញផ្តល់ "សេវាទូទាត់រហ័ស" របស់ខ្លួនតាមរយៈសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត និងតាមរយៈបណ្តាញផ្សេងៗ។

### ៣.១.៣. ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS)

ប្រព័ន្ធខេមបូឌានស៊ែស្វីចមានសមាជិកសរុបចំនួន ៥៨ គ្រឹះស្ថាន ដែលក្នុងនោះមានសមាជិកមិនផ្ទាល់ចំនួន ៣។ ក្នុងចំណោមគ្រឹះស្ថានសមាជិកទាំង ៥៨ មានគ្រឹះស្ថានសមាជិកចំនួន ៥៥ (ក្នុងនោះមានគ្រឹះស្ថានសមាជិកមិនផ្ទាល់ចំនួន ៣) បានដាក់ឱ្យប្រព័ន្ធដំណើរការបឋម ខណៈគ្រឹះស្ថានសមាជិកដទៃទៀតកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍផ្សេងៗគ្នា។ ការដាក់ឱ្យដំណើរការប្រព័ន្ធខេមបូឌានស៊ែស្វីចអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការប័ណ្ណឥណពន្ធរបស់ខ្លួនលើគ្រប់ម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានសមាជិកដែលមានស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច និងផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ទាំងនោះធ្វើប្រតិបត្តិការទូទាត់យ៉ាងសម្បូរបែបតាមប្រព័ន្ធនេះគ្រប់ពេលវេលា (២៤/៧) ដែលនឹងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ប័ណ្ណឥណពន្ធ និងអន្តរប្រតិបត្តិការម៉ាស៊ីន ATM និង POS ដែលសម្រួលដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការអន្តរធនាគារ និងកាត់បន្ថយការចំណាយវិនិយោគលើម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានសមាជិក។

ក្នុងឆ្នាំ២០២២ នេះ ប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់រៀលដែលបានចូលទូទាត់តាមប្រព័ន្ធខេមបូឌានស៊ែស្វីចមានចំនួន ៣៧៧.១៤០ ប្រតិបត្តិការ (កើនឡើង ១៨,៤៧%) និងទំហំប្រាក់មានចំនួន ៨៦,២១ ប៊ីលានរៀល (កើនឡើង ១៣,១%)។ ជាមួយគ្នានេះ ចំនួនប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់ដុល្លារអាមេរិកមានចំនួន ៨៤.៧៥៩ ប្រតិបត្តិការ (ថយចុះ ២%) និងទំហំប្រាក់មានចំនួន ១១,៨៦ លានដុល្លារអាមេរិក (កើនឡើង ១៤,០៤%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមតាមប្រព័ន្ធខេមបូឌានស៊ែស្វីចមានទំហំប្រមាណ ០,១១% នៃផ.ស.ស។

**តារាង ៧ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធ CSS**

| ឆ្នាំ | ប្រតិបត្តិការប័ណ្ណឥណពន្ធ ជាប្រាក់រៀល | | ប្រតិបត្តិការប័ណ្ណឥណពន្ធ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាលានរៀល) | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ២៨.៣៥៩ | ៤.៩០២,០៦ | ១៤.៦៤៦ | ១,៥៤ |
| ឆ១ - ២០២០ | ៦៦.៥៩៥ | ១២.៨៦៨,៤៩ | ១៧.៤៧៣ | ១,៦៤ |
| ឆ២ - ២០២០ | ១៤១.២៨៣ | ២៩.៨៦១,៦៣ | ៣០.៣២៧ | ៣,២៥ |
| ឆ១ - ២០២១ | ១៦០.៤៨៨ | ៣៥.៦៨៣,៤៧ | ៤៣.១០២ | ៥,០២ |
| ឆ២ - ២០២១ | ១៥៧.៨៥២ | ៤០.៥៤៤,៨៦ | ៤៣.៣៩១ | ៥,៣៥ |
| ឆ១ - ២០២២ | ១៩៨.៤១៥ | ៤៦.៧៤២,០៦ | ៤៨.១៥៦ | ៦,៦៦ |
| ឆ២ - ២០២២ | ១៧៨.៧២៥ | ៣៩.៤៧៤,២១ | ៣៦.៦០៣ | ៥,២០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា



**ក្រាហ្វ ១១ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធ CSS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ៣.១.៤. ប្រព័ន្ធធនាគារអនឡាញ (OBS)

បច្ចុប្បន្ន ប្រព័ន្ធធនាគារអនឡាញមានសមាជិកសរុបចំនួន ៧៩ គ្រឹះស្ថាន ដែលក្នុងនោះមានធនាគារពាណិជ្ជចំនួន ៥៥ ធនាគារឯកទេសចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១៥ និងស្ថាប័នរដ្ឋចំនួន ១ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។

ក្នុងឆ្នាំ២០២២ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS មាន ៥៤.៦៧១ ប្រតិបត្តិការ ដែលក្នុងនោះ ការផ្ទេរប្រាក់ក្នុងចំណោមគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមាន ៥៣.៥៨៤ ប្រតិបត្តិការ និងការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តមាន ១.០៨៧ ប្រតិបត្តិការ។ ការផ្ទេរប្រាក់ជាប្រាក់រៀលរវាងគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមានចំនួន ៣៣.៥៨៤ ប្រតិបត្តិការ (កើនឡើង ២៤,៨%) ស្មើនឹងទំហំប្រាក់ ៩១,២ ទ្រីលានរៀល (កើនឡើង ១២,៧%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ២០.០០០ ប្រតិបត្តិការ (កើនឡើង ៣១,២%) ស្មើទំហំប្រាក់ ៥៩,៦ ប៊ីលានដុល្លារអាមេរិក (កើនឡើងប្រមាណ ៣៨,៩%)។ ក្នុងរយៈពេលដូចគ្នានេះ ប្រតិបត្តិការផ្ទេរប្រាក់ជាប្រាក់រៀល ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តមានចំនួន ៥៥៤ ប្រតិបត្តិការ (ថយចុះ ៣៩,៨%) ស្មើទំហំប្រាក់ ២,៥ ទ្រីលានរៀល (ថយចុះ ២៥,៧%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៣៣ ប្រតិបត្តិការ (ថយចុះ ៣៦%) ស្មើទំហំប្រាក់ ៩៨១ លានដុល្លារអាមេរិក (ថយចុះ ៥,៩%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធ OBS មានទំហំប្រមាណ ២៨២% នៃផ.ស.ស។



ក្នុងរយៈពេលដំណើរការប្រមាណ ៧ ឆ្នាំកន្លងមកនេះ ប្រព័ន្ធ OBS នៅតែជាប្រព័ន្ធដែលមានប្រជាប្រិយភាព។ យ៉ាងណាមិញ ធនាគារជាតិនៃកម្ពុជានៅតែបន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់ប្រព័ន្ធនេះឱ្យបានកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីជំរុញការទូទាត់សងប្រាក់ជាអេឡិចត្រូនិក និងសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ឱ្យកាន់តែងាយស្រួល និងសុវត្ថិភាព។

**តារាង ៨ - ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលតាមប្រព័ន្ធ OBS**

| ឆ្នាំ | ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល | | | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការជាប្រាក់រៀល | ទំហំប្រាក់ (គិតជាទ្រីលានរៀល) | ចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៧.៥៤៤ | ២៥,៧៩ | ៤.៥៤៣ | ១៤.៣៩៥,៥៥ |
| ឆ១ - ២០២០ | ១១.៤៣៨ | ៤៣ | ៥.៣៣៨ | ១៥.៩៦១,៩០ |
| ឆ២ - ២០២០ | ៩.៥២២ | ២៩ | ៥.៩៩២ | ១៥.៨៧៥,១៩ |
| ឆ១ - ២០២១ | ១២.២១២ | ៤០,១៣ | ៦.៥៩២ | ១៩.៧២៧,៨៥ |
| ឆ២ - ២០២១ | ១៤.៦៩៦ | ៤០,៧៦ | ៨.៦៥៥ | ២៣.១៤២,៩៥ |
| ឆ១ - ២០២២ | ១៦.៣៧៣ | ៤៦,៦៨ | ១០.៤១៩ | ៣១.៣៨៤,៧៣ |
| ឆ២ - ២០២២ | ១៧.២១១ | ៤៤,៥០ | ៩.៥៨១ | ២៨.១៦៦,០៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**តារាង ៩ - ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត តាមប្រព័ន្ធ OBS**

| ឆ្នាំ | ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត | | | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការជាប្រាក់រៀល | ទំហំប្រាក់ (គិតជាទ្រីលានរៀល) | ចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៣៨០ | ១,៤ | ២១៦ | ២៩០,២១ |
| ឆ១ - ២០២០ | ៣៦៥ | ១ | ៣៨១ | ៣២៧,០២ |
| ឆ២ - ២០២០ | ៥៦៨ | ១,៥ | ៤៧២ | ៤២៩,៣៩ |
| ឆ១ - ២០២១ | ៥៣៥ | ២ | ៤៥០ | ៥៣២,១៥ |
| ឆ២ - ២០២១ | ៣៨៦ | ១,៣ | ៣៨៤ | ៥០៩,៩៦ |
| ឆ១ - ២០២២ | ៣៣៦ | ១,៥ | ៣៣៥ | ៦៩២,៥២ |
| ឆ២ - ២០២២ | ២១៨ | ១ | ១៩៨ | ២៨៨,៥០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា



**ក្រាហ្វ ១២ - ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធ OBS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ៣.១.៥. ប្រព័ន្ធរីថៃលផេ (Retail Pay)

ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធរីថៃលផេ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ដែលប្រព័ន្ធនេះមានប្រព័ន្ធរងចំនួន ៤ គឺ ១/-ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (RFT) ២/-ប្រព័ន្ធទូទាត់ចល័ត (MPS) ៣/-ប្រព័ន្ធទូទាត់តាម QR (QPS) និង ៤/-ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក (ECS) ដែលក្នុងចំណោមប្រព័ន្ធទាំង ៤ មានតែប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ និងប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក ប៉ុណ្ណោះដែលដាក់ឱ្យប្រើប្រាស់ ចំណែកប្រព័ន្ធផ្សេងទៀតកំពុងធ្វើសន្ទានកម្មនៅឡើយ។

បច្ចុប្បន្ន ប្រព័ន្ធរីថៃលផេមានគ្រឹះស្ថានសមាជិកសរុបចំនួន ២៣ ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ១៦ បានដាក់ឱ្យដំណើរការប្រព័ន្ធរីថៃលផេជាសាធារណៈតាមគ្រប់បណ្ដាញប្រតិបត្តិការរបស់ខ្លួនដែលរួមមាន ការធ្វើប្រតិបត្តិការតាមបញ្ជររបស់គ្រឹះស្ថាន និងតាមបណ្ដាញសេវាធនាគារចល័តរបស់ខ្លួន ដោយអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគាររវាងគ្រឹះស្ថានជាសមាជិកបានប្រកបដោយភាពងាយស្រួល រហ័ស សុវត្ថិភាព និងប្រសិទ្ធភាព។

ក្នុងឆ្នាំ២០២២ ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT ជាប្រាក់រៀល មានចំនួន ២៦.៦៦០ ប្រតិបត្តិការ (ថយចុះ ២២,៥%) ខណៈដែលមានទំហំប្រាក់ជាប្រាក់រៀល ៤៦៤,៣៩



លានរៀល (កើនឡើង ១៥,៦%)។ ជាមួយគ្នានោះ ចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ចំនួន ៥៦.៧៧៣ ប្រតិបត្តិការ (ថយចុះ ២៩,៦%) ខណៈដែលទំហំប្រាក់ ២៥០,៣០ លានដុល្លារអាមេរិក (កើនឡើង ១៨,៦%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធរីផែលផេ មានទំហំប្រមាណ ១,២% នៃផ.ស.ស។

**តារាង ១០ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT**

| ឆ្នាំ | បញ្ជាផ្ទេរ ជាប្រាក់រៀល | | បញ្ជាផ្ទេរ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាលានរៀល) | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ១ - ២០២០ | ១.៧២០ | ១០.៧០៣,២៣ | ២.៧៩៧ | ១៦,០៨ |
| ឆ២ - ២០២០ | ៧.៣០២ | ៣៣.៥៥៨,១៦ | ១២.៦០០ | ៤១,៤៩ |
| ឆ១ - ២០២១ | ១៥.៥៥៥ | ១២២.៧៤៨,៤៧ | ៣០.៤១៧ | ៨៧,៨៤ |
| ឆ២ - ២០២១ | ១៨.៨២៧ | ២៧៩.០០៧,៥៣ | ៣៦.០០៩ | ១១៤,៨៣ |
| ឆ១ - ២០២២ | ១៣.៦៨៤ | ២៦១.៣៣៤,២៧ | ២១.៨៨៨ | ១១៨,២៨ |
| ឆ២ - ២០២២ | ១២.៩៧៦ | ២០៣.០៦០,៤៧ | ២៤.៨៨៥ | ១២២,០២ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៣ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



បច្ចុប្បន្ន ក្នុងចំណោមប្រព័ន្ធទូទាត់ចម្បងៗដែលកំពុងធ្វើប្រតិបត្តិការក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ប្រព័ន្ធផាត់ទាត់ជាតិជាប្រព័ន្ធដែលពេញនិយមប្រើប្រាស់ច្រើនជាងប្រព័ន្ធផ្សេងៗទៀត បើផ្អែកលើចំនួនប្រតិបត្តិការ ដូចមានបង្ហាញក្នុងក្រាហ្វខាងក្រោម៖

**ក្រាហ្វ ១៤ - ចំនួន និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣.២. ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់

ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានអនុវត្តឡើងក្នុងគោលបំណងកាត់បន្ថយហានិភ័យចម្បងៗដែលអាចកើតមានក្នុងប្រព័ន្ធទូទាត់ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ។

### ៣.២.១. ការគ្រប់គ្រងហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ និងហានិភ័យឥណទាន

ដើម្បីបង្ការនូវហានិភ័យក្នុងប្រព័ន្ធផាត់ទាត់ជាតិ ធនាគារជាតិនៃកម្ពុជាបានរៀបចំយន្តការដោះស្រាយ និងគ្រប់គ្រង ដូចខាងក្រោម៖

- រៀបចំប្រព័ន្ធតាមដានសន្ទនីយភាព ដើម្បីអនុញ្ញាតឱ្យសមាជិកនីមួយៗអាចពិនិត្យមើលសមតុល្យមូលនិធិដែលមានក្នុងគណនីទូទាត់ជាប្រចាំ
- ផ្តល់សន្ទនីយភាពក្នុងថ្ងៃដល់សមាជិកដែលជួបប្រទះកង្វះខាតសាច់ប្រាក់ ក្នុងការទូទាត់



(ឥណទានវិបារូបន៍ដោយមានវត្ថុធានា)
- សមាជិកអាចស្នើសុំឥណទានវិបារូបន៍ស្មើនឹង ១០០% នៃតម្លៃប្រាតិភោគ
- ប្រសិនបើសមាជិកពុំមានសន្ទនីយភាពគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធពហុភាគីរបស់ខ្លួនតាមពេលកំណត់ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជាអាចពន្យារពេលបិទការទូទាត់ ដើម្បីឱ្យសមាជិកដែលខ្វះសន្ទនីយភាពមានពេលវេលាបន្ថែមក្នុងការសម្របសម្រួលរកសន្ទនីយភាពពីប្រភពផ្សេងៗសម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធ។ ក្នុងករណីនេះ សមាជិកនោះនឹងត្រូវរងពិន័យក្នុងការបណ្តាលឱ្យមានការពន្យារការទូទាត់
- ការផាត់ទាត់ឡើងវិញ (Unwinding of Clearing) ជាមធ្យោបាយចុងក្រោយ ដែលអាចត្រូវបានអនុវត្តនៅពេលដែលសមាជិកផ្ទាល់ណាមួយគ្មានលទ្ធភាពរកសន្ទនីយភាពសម្រាប់បំពេញកាតព្វកិច្ចទូទាត់បានទាន់ពេលវេលា។ ប្រសិនបើមានករណីនេះកើតឡើង ការផាត់ទាត់ត្រូវធ្វើឡើងវិញ ហើយរាល់អ៊ីនភុតឧបករណ៍ដែលត្រូវទូទាត់របស់សមាជិកទាំងអស់ត្រូវបញ្ជូនជាថ្មីមកសភាផាត់ទាត់ជាតិ ដើម្បីដំណើរការផាត់ទាត់ និងទូទាត់ឡើងវិញ លើកលែងតែឧបករណ៍ទូទាត់របស់សមាជិកដែលគ្មានលទ្ធភាពទូទាត់សងត្រូវបានដកចេញទាំងអស់
- បញ្ចូលឈ្មោះអតិថិជនដែលចេញមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ទៅកាន់ប្រព័ន្ធរបស់ការិយាល័យឥណទានកម្ពុជា (CBC)។

### ៣.២.២. ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ

ដើម្បីគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធក្នុងប្រព័ន្ធផាត់ទាត់ជាតិឱ្យដំណើរការប្រតិបត្តិការដោយរលូន ធនាគារជាតិនៃកម្ពុជាបានរៀបចំយន្តការគ្រប់គ្រងដូចជា រៀបចំប្រព័ន្ធសម្រាប់សង្គ្រោះទិន្នន័យពេញលេញដែលបានបំពាក់នៅស្នាក់ការកណ្តាលនៃធនាគារជាតិនៃកម្ពុជា និងនៅមណ្ឌលសង្គ្រោះ។ ប្រព័ន្ធសង្គ្រោះទិន្នន័យនៅស្នាក់ការកណ្តាលមានសមត្ថភាពបច្ចេកទេសរឹងមាំធន់នឹងគ្រោះមហន្តរាយជាអតិបរមា ដែលអាចធានាការស្រោចស្រង់ទិន្នន័យបានភ្លាមៗដោយស្វ័យប្រវត្តិ និងអាចដំណើរការវិញក្នុងរយៈពេលមួយម៉ោង។ ទន្ទឹមនឹងនោះ ក្នុងករណីមានភាពរអាក់រអួលនៃប្រព័ន្ធប្រតិបត្តិការរបស់សមាជិកណាមួយ ធនាគារជាតិនៃកម្ពុជាផ្តល់យន្តការសម្រួលភ្លាមៗនៅនឹងកន្លែងជា Back-Up Bureau Services ចំពោះសមាជិកណាដែលមិនអាចបញ្ជូនទិន្នន័យជាអេឡិចត្រូនិកមកសភាផាត់ទាត់ជាតិបានដោយសារបញ្ហាផ្នែកបច្ចេកទេស។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំជា Secondary site ដោយបំពាក់ឧបករណ៍កុំព្យូទ័រ Software និង Hardware ក្នុងករណីមានករណីប្រធានសក្តិ ឬជំងឺឆ្លងដែលមិនអាចចូលមកកន្លែងធ្វើការបាន។

ក្នុងឆ្នាំ២០២២ ទោះបីជាបានជួបបញ្ហារអាក់រអួលផ្នែកបច្ចេកទេសខ្លះៗដែលបណ្តាលមកពីដាច់បណ្តាញប្រព័ន្ធ មិនអាចទំនាក់ទំនងជាមួយប្រព័ន្ធធនាគារស្នូលបានក៏ដោយ ប៉ុន្តែបញ្ហានេះត្រូវបានដោះស្រាយភ្លាមៗទាន់ពេលវេលា។ ដោយឡែក ចំពោះការពន្យារពេលទូទាត់ដោយមូលហេតុ

កង្វះសន្ទនីយភាពពុំធ្លាប់ជួបប្រទះឡើយ ដោយសារសមាជិកនីមួយៗបានយកចិត្តទុកដាក់ក្នុងការពិនិត្យតាមដានសមតុល្យនៅក្នុងគណនីទូទាត់ ដើម្បីធានាថាមានមូលនិធិគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចទូទាត់នៅក្នុងថ្ងៃ។ ជារួម ប្រព័ន្ធផាត់ទាត់ជាតិបានដំណើរការដោយរលូន ដែលបច្ចុប្បន្នប្រព័ន្ធនេះអាចរក្សាបាននូវការអនុវត្តសម្រេចបានកម្រិតស្តង់ដារបច្ចេកទេស ៩៥% នៃរង្វាស់គោល ១០០%។ ការអនុវត្តប្រចាំថ្ងៃត្រូវបានគណនាដោយធៀបនឹងកម្រិតគោលសម្រាប់ដំណើរការប្រចាំថ្ងៃ ដូចជា ពេលវេលាផាត់ទាត់និងទូទាត់ជាក់ស្តែង (៨០%) ពេលវេលាចាប់ផ្តើមជាក់ស្តែងក្នុងថ្ងៃ (៥%) ម៉ោងឈប់ទទួល Input (៥%) ពេលវេលាទូទាត់ជាក់ស្តែង (៥%) ព្រមទាំងបញ្ហាផ្សេងៗនៃកិច្ចដំណើរការជាក់ស្តែងដែលកើតឡើងដោយសារការធ្វើបច្ចុប្បន្នកម្ម និងការផ្លាស់ប្តូរកម្មវិធី (៥%)។

## ៣.៣. ស្តង់ដារឧបករណ៍ និងបណ្តាញប្រព័ន្ធទូទាត់សងប្រាក់

ការអនុវត្តស្តង់ដាររួមស្របតាមនវានុវត្តន៍អន្តរជាតិនឹងសម្រួលដល់ការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់សងប្រាក់ទាំងក្នុងស្រុក និងក្នុងតំបន់។ ម្យ៉ាងវិញទៀត ការដាក់ឱ្យប្រើប្រាស់ស្តង់ដាររួមនេះ អាចការពារអតិថិជនទាក់ទងនឹងការក្លែងបន្លំ និងផ្តល់លទ្ធភាពក្នុងការធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថាន។

### ៣.៣.១. ស្តង់ដារលេខអត្តសញ្ញាណធនាគារ

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលមានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតម្រូវការសាធារណជន និងដើម្បីគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចជារួម។ ក្នុងន័យនេះ ក្នុងគោលបំណងលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផាត់ទាត់ជាតិលើឧបករណ៍មូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ ដែលជាស្តង់ដារលេខអត្តសញ្ញាណធនាគារប្រើប្រាស់សម្រាប់សម្គាល់គ្រឹះស្ថានធនាគារ និងសាខាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលជាសមាជិកប្រព័ន្ធផាត់ទាត់ជាតិ។

### ៣.៣.២. មូលប្បទានបត្រស្តង់ដារ

ក្នុងគោលបំណងឱ្យមានការឯកភាពជាលក្ខណៈស្តង់ដារនូវមូលប្បទានបត្រដែលប្រើប្រាស់ក្នុងប្រព័ន្ធធនាគារ និងដើម្បីឱ្យការទូទាត់និងផាត់ទាត់អន្តរធនាគារប្រព្រឹត្តទៅដោយពិលាស និងមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨។ ប្រកាសនេះក៏មានភ្ជាប់ជាមួយនូវសេចក្តីណែនាំស្តីពី លក្ខណៈស្តង់ដារនៃមូលប្បទានបត្រដែលជាឧបសម្ព័ន្ធដោយបានកំណត់ពីទំហំមូលប្បទានបត្រ លេខកូត និទ្ទេសព្រមទាំងមានចារឹកតួលេខ និងសញ្ញាពិសេសដែលអាចអានបានដោយម៉ាស៊ីន និងអនុសាសន៍លើការការពារការក្លែងបន្លំជាដើម។



### ៣.៣.៣. គំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានជាអេឡិចត្រូនិក

កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្ដីពីការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ដែលជាគំរូលាយលក្ខណ៍អក្សរ ឬអេឡិចត្រូនិកសម្រាប់ការផ្ទេរប្រាក់ពីគណនីទៅគណនីជាអេឡិចត្រូនិក។

### ៣.៣.៤. ការកំណត់ស្ដង់ដារលេខអត្តសញ្ញាណធនាគារលើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក

ក្នុងគោលបំណងរក្សាសង្គតិភាពនៃការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក និងងាយស្រួលក្នុងការកត់សម្គាល់ប័ណ្ណទូទាត់ចេញផ្សាយដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ធនាគារជាតិនៃកម្ពុជាបានកំណត់ស្ដង់ដារលេខអត្តសញ្ញាណធនាគារ (Bank Identification Number - BIN) លើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក (៩១១៦) ដែលមានចែងក្នុងវិធាននិងនីតិវិធីប្រព័ន្ធ CSS។

### ៣.៣.៥. ការកំណត់ស្ដង់ដារ Chip EMV សម្រាប់ប័ណ្ណទូទាត់ក្នុងស្រុក

ដើម្បីលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពក្នុងប្រព័ន្ធខេមបូឌានស៊ែស្វីច និងរក្សាជំនឿទុកចិត្តនិងការកាពារអតិថិជនលើការប្រើប្រាស់ប័ណ្ណទូទាត់ ធនាគារជាតិនៃកម្ពុជាបានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រើប្រាស់ស្ដង់ដារ Chip EMV លើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុករបស់ខ្លួន តាមរយៈសេចក្ដីជូនដំណឹងស្ដីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូឌានស៊ែស្វីច ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

### ៣.៣.៦. ការអនុវត្តគោលការណ៍សុវត្ថិភាពលើម៉ាស៊ីន ATM និង/ឬ POS

ក្រៅពីការកំណត់ស្ដង់ដារនៃឧបករណ៍ទូទាត់ ធនាគារជាតិនៃកម្ពុជាបានជំរុញគ្រប់គ្រឹះស្ថានសមាជិកប្រព័ន្ធ CSS ដែលដាក់ឱ្យដំណើរការម៉ាស៊ីន ATM និង/ឬ POS ត្រូវអនុវត្តគោលការណ៍សុវត្ថិភាពនៅលើម៉ាស៊ីន ATM និង/ឬ POS ដូចមានចែងក្នុងឧបសម្ព័ន្ធ១១ "គោលការណ៍សុវត្ថិភាពលេខសម្ងាត់ (PIN) និងទិន្នន័យប័ណ្ណ" នៃវិធាននិងនីតិវិធីប្រព័ន្ធ CSS រួមមាន (១) EPP shield and/or Anti-PIN pad Overlay (២) Anti-card Skimming (៣) Anti-card Trapping និង (៤) PCI-DSS compliance។

### ៣.៣.៧. ខេអេចឃ្យូអរកូត (KHQR Code)

ឧបករណ៍ទូទាត់ និងបណ្ដាញទូទាត់បានវិវត្តន៍ស្របតាមតម្រូវការ និងបច្ចេកវិទ្យាទៅកាន់ការទូទាត់តាម QR Code ហើយឧបករណ៍ទូទាត់នេះមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារចំណាយទាបជាងបណ្ដាញទូទាត់ និងឧបករណ៍ទូទាត់ផ្សេងៗ និងមានភាពងាយស្រួល។ កន្លងមកស្លាកសញ្ញា QR Code របស់គ្រឹះស្ថានជាច្រើនតាំងនៅតាមពាណិជ្ជករ ការណ៍នេះ មិនបានផ្ដល់ភាពងាយស្រួលដល់អតិថិជនក្នុងការស្កេនដើម្បីទូទាត់ និងមិនមានលទ្ធភាពទូទាត់អន្តរគ្រឹះស្ថានបាន។



អាស្រ័យហេតុនេះ ដើម្បីបង្កើនប្រសិទ្ធភាពទូទាត់ និងសណ្តាប់ធ្នាប់នៃការទូទាត់តាម QR Code ជាពិសេសជំរុញការទូទាត់តាម QR Code ឆ្លងគ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាស ស្តីពី គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូតសម្រាប់ការទូទាត់សងប្រាក់ កាលពីថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០២០ និងបានជ្រើសរើសយកប្រព័ន្ធបាគងជាមជ្ឈមណ្ឌលទូទាត់។

### ៣.៣.៨. ស្តង់ដារសារ ISO ២០០២២

ធនាគារកណ្តាលនៃសហគមប្រទេសអាស៊ានបានសម្រេចជ្រើសយកស្តង់ដារសារ ISO ២០០២២ ជាស្តង់ដារសារសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនៃប្រទេសជាសមាជិកអាស៊ាន។ បណ្តាធនាគារកណ្តាលនៃប្រទេសសហគមអាស៊ានត្រូវត្រៀមខ្លួនជាស្រេចសម្រាប់ស្តង់ដារ ISO ២០០២២ នេះ។ អនុលោមតាមនវានុវត្តន៍អន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានទទួល និងប្រើប្រាស់ស្តង់ដារសារ ISO ២០០២២ នេះទាំងប្រព័ន្ធទូទាត់រាយ និងប្រព័ន្ធទូទាត់តម្លៃធំ ដែលកំពុងអភិវឌ្ឍ។



# ៤ ការគ្រប់គ្រងសេវាទូទាត់សងប្រាក់ និងការផ្ទេរប្រាក់ឆ្លងដែន

## ៤.១. ការគ្រប់គ្រងសេវាទូទាត់សងប្រាក់

### ៤.១.១. ទិដ្ឋភាពទូទៅ និងការវិវត្តន៍

ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បានធ្វើឱ្យសេវាទូទាត់សងប្រាក់មានការរីកចម្រើនប្រកបដោយសុខុមាលភាព និងបានវិវត្តន៍ទៅរកការទូទាត់បែបឌីជីថល ឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនលើការប្រើប្រាស់សេវាទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍ ងាយស្រួល សុវត្ថិភាព និងចំណាយទាប។ គិតត្រឹមឆ្នាំ២០២២ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាមានចំនួន ៣៥ គ្រឹះស្ថាន និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២ ទទួលបានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការទូទាត់សងប្រាក់ពីធនាគារជាតិនៃកម្ពុជា។ ជាទូទៅ គំរូផលិតផល និងសេវាដែលផ្តល់ដោយគ្រឹះស្ថានទាំងនេះ មានលក្ខណៈជាការទូទាត់បែបឌីជីថល ដែលអតិថិជនអាចធ្វើប្រតិបត្តិការដោយផ្ទាល់តាមរយៈកម្មវិធីទូទាត់ចល័ត ឬនៅតាមបញ្ជរភ្នាក់ងារ និងបណ្តាញទូទាត់ជាច្រើនដែលគ្របដណ្តប់ទូទាំងប្រទេស។

នៅលើទីផ្សារបច្ចុប្បន្ន អតិថិជនបានផ្លាស់ប្តូរឥរិយាបទពីការចាយវាយដោយពឹងផ្អែកលើសាច់ប្រាក់មកជាការទូទាត់បែបឌីជីថល ជាពិសេសក្នុងស្រទាប់យុវវ័យ ការណ៍នេះធ្វើឱ្យការប្រើប្រាស់សេវាទូទាត់សងប្រាក់មានការកើនឡើងគួរឱ្យកត់សម្គាល់។ គិតត្រឹមឆ្នាំ២០២២ ទិន្នន័យអតិថិជនចុះឈ្មោះបង្កើតគណនីអ៊ីវ៉ាឡេតសរុបមានចំនួន ១៩,៥ លាននាក់ កើនឡើង ៤២,៩% និងភ្នាក់ងារមានចំនួនសរុប ៥២,៣ ពាន់ទីតាំង ដែលមានការកើនឡើង ១២,៩% ធៀបនឹងឆ្នាំ២០២១។ ចំណែកឯចំនួនប្រតិបត្តិការសរុបក្នុងឆ្នាំ២០២២ មានការកើនឡើង ៣៥,៩% ពី ៣៤៣,៨ ទៅ ៤៦៧,៤ លានប្រតិបត្តិការ និងទំហំប្រាក់កើនឡើង ៣១,០២% ពី ៤៩,១ ទៅ ៦៤,៣ ប៊ីលានដុល្លារអាមេរិក ធៀបនឹងឆ្នាំ២០២១ ប្រមាណ ២១៨,៦% នៃផ.ស.ស។ ទន្ទឹមនឹងការរីកចម្រើននេះ ការគ្រប់គ្រងមូលនិធិរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្តល់សេវាទូទាត់សងប្រាក់ក៏មានភាពល្អប្រសើរផងដែរ ដោយជាទូទៅគ្រឹះស្ថានរក្សាបាននូវសមតុល្យក្នុងគណនីអាណត្តិព្យាបាលបានខ្ពស់ជាងសមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ ដើម្បីធានាផលប្រយោជន៍ដល់អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់។ គិតត្រឹមឆ្នាំ២០២២ សមតុល្យប្រាក់សរុបដែលបានរក្សាទុកក្នុងគណនីអាណត្តិព្យាបាលមានចំនួន ២៨៧,៦ លានដុល្លារអាមេរិក និងសមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយមានចំនួន ២៨៦,៦ លានដុល្លារអាមេរិក។



**ក្រាហ្វ ១៥ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះអ៊ីវ៉ាឡេត និងអតិថិជន Walk-in របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័តតាមកាបូបអេឡិចត្រូនិក (Mobile E-wallet)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៧ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



ទន្ទឹមគ្នានេះដែរ សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត (Internet and Mobile Banking) ដែលដាក់ឱ្យដំណើរការតាមរយៈគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់អតិថិជនរបស់ខ្លួនប្រើប្រាស់ បានយ៉ាងទូលំទូលាយ លើសេវាទូទាត់ដូចជា ការទូទាត់ឥណទាន ការទូទាត់វិក្កយបត្រ (ថ្លៃទឹក/ភ្លើង អ៊ីនធឺណិត ទូរទស្សន៍ខ្សែកាប ធានារ៉ាប់រង) សេវាបញ្ចូលប្រាក់ទូរស័ព្ទ សេវាបើកប្រាក់បៀវត្សរ៍ និង សេវាទូទាត់ផ្សេងៗទៀត ដូចជាការផ្ទេរមូលនិធិ និងការពិនិត្យមើលសមតុល្យនៅក្នុងគណនីជាដើម។

គិតត្រឹមឆ្នាំ២០២២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៨ គ្រឹះស្ថាន បានផ្តល់សេវាធនាគារអ៊ីនធឺណិត និងគ្រឹះស្ថានចំនួន ៣៣ ផ្សេងទៀតបានផ្តល់សេវាធនាគារចល័ត។ ចំពោះចំនួនប្រតិបត្តិការតាមរយៈសេវាធនាគារអ៊ីនធឺណិតក្នុងឆ្នាំ២០២២ មានការថយចុះ ២៤,៧% ពី ៤,៤ មកត្រឹម ៣,៣ លានប្រតិបត្តិការ និងទំហំប្រាក់មានការថយចុះ ១១,៥% ពី ២២,២ មកត្រឹម ១៩,៧ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៦៦,៨% នៃផ.ស.ស។ ចំណែកឯ ចំនួនប្រតិបត្តិការរបស់សេវាធនាគារចល័តមានការកើនឡើង ៩០,៩% ពី ២៥៤,១ ទៅ ៤៨៥,១ លានប្រតិបត្តិការ និងទំហំប្រាក់មានការកើនឡើង ៤៧,៨% ពី ១១១,៤ ទៅ ១៦៤,៧ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៥៦០,១% នៃផ.ស.ស។

**ក្រាហ្វ ១៨ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



ប័ណ្ណទូទាត់ ជាឧបករណ៍ទូទាត់សងប្រាក់ពេញនិយមដែលមានការប្រើប្រាស់កាន់តែច្រើនឡើង គួរឱ្យកត់សម្គាល់ផងដែរ ជាពិសេសប័ណ្ណទូទាត់ ដែលមានដូចជា ប័ណ្ណឥណពន្ធ (Debit Card) ប័ណ្ណ

ឥណទាន (Credit Card) ប័ណ្ណទូទាត់ក្នុងស្រុក (Proprietary Card) និងប័ណ្ណបង់ប្រាក់ជាមុន (Prepaid Card) ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ការទូទាត់តម្លៃរាយ និងតាមប្រព័ន្ធអនឡាញ។

គិតត្រឹមឆ្នាំ២០២២ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤២ បានចេញផ្សាយប័ណ្ណទូទាត់សម្រាប់អតិថិជនរបស់ខ្លួន ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការទូទាត់សងប្រាក់។ ប័ណ្ណទូទាត់ដែលបានចេញផ្សាយមានចំនួនសរុប ១២,៣ លានប័ណ្ណ និងប្រតិបត្តិការទូទាត់តាមប័ណ្ណទូទាត់ក្នុងស្រុកសរុបក្នុងឆ្នាំ២០២២ មានការកើនឡើង ១២,៥% ពី ៨៧,៤ ទៅ ៩៨,៣ លានប្រតិបត្តិការ និងទំហំប្រាក់កើនឡើង ៩,៨% ពី ២០,៥ ទៅ ២២,៥ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៧៦,៤% នៃផ.ស.ស។

ដោយឡែក ចំនួនប្រតិបត្តិការប័ណ្ណទូទាត់នៅក្រៅប្រទេសមានការថយចុះចំនួន ១៨,៣% ពី ២,៧ មកត្រឹម ២,២ លានប្រតិបត្តិការ ដែលការថយចុះនៃចំនួនប្រតិបត្តិការប័ណ្ណទូទាត់នៅក្រៅប្រទេសនេះបណ្តាលមកពីការបិទខ្ទប់អំឡុងពេលជំងឺកូវីដ-១៩ ស្មើនឹងទំហំប្រាក់ ១ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៣,៣% នៃផ.ស.ស។ ចំណែកឯប្រតិបត្តិការទូទាត់ទំនិញតាមប្រព័ន្ធអនឡាញសរុបមានការកើនឡើង ៣៣,៥% ពី ១៤,៤ ទៅ ១៩,២ លានប្រតិបត្តិការ និងទំហំប្រាក់មានការកើនឡើង ៣៥,២% ពី ០,៥ ទៅ ០,៧ ប៊ីលានដុល្លារអាមេរិក ប្រមាណ ២,៣% នៃផ.ស.ស។ ស្របគ្នានេះដែរ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៩ គ្រឹះស្ថាន បានតម្លើងម៉ាស៊ីនដក/ដាក់ប្រាក់ចំនួន ៤,៤ ពាន់គ្រឿង និង ៣៦ គ្រឹះស្ថានបានតម្លើងម៉ាស៊ីនឆូតកាតចំនួន ៥៤,១ ពាន់គ្រឿង នៅទូទាំងប្រទេសកម្ពុជា។

**ក្រាហ្វ ១៩ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២០ - ចំនួនម៉ាស៊ីន ATM និងម៉ាស៊ីន POS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បន្ទាប់ពីដាក់ឱ្យដំណើរការស្តង់ដារខេអេចយូអរកូត (KHQR Code) ដែលជួយសម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានបានធ្វើឱ្យការទូទាត់សងប្រាក់តាមយូអរកូត (QR Code) កាន់តែមានការពេញនិយមប្រើប្រាស់ក្នុងការទូទាត់បែបអេឡិចត្រូនិកជំនួសឱ្យការទូទាត់ជាសាច់ប្រាក់ ដោយសារការទូទាត់សងប្រាក់តាមយូអរកូតនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អតិថិជនដូចជា ទូទាត់ទំនិញបានរហ័ស ចំណេញពេលវេលា កម្រៃសេវាសមរម្យ និងសុវត្ថិភាព។ ការណ៍នេះ ធ្វើឱ្យអតិថិជនកាន់តែមានទំនុកចិត្តក្នុងការប្រើប្រាស់ និងទទួលបានបទពិសោធន៍ថ្មីពីសេវាទូទាត់តាម QR Code នេះ។ ក្នុងឆ្នាំ២០២២ ចំនួនប្រតិបត្តិការទូទាត់តាម QR Code មានការកើនឡើងជាលំដាប់ ដោយប្រតិបត្តិការមានចំនួន ២៣,៣ លាន កើនឡើង ៤៣០% ធៀបនឹងឆ្នាំ២០២១ ស្មើនឹងទំហំប្រាក់ចំនួន ៣.៣៥៧,៦ លានដុល្លារអាមេរិក ប្រមាណ ១១,៤% នៃផ.ស.ស។

**ក្រាហ្វ ២១ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ៤.១.២. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ និងគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ អភិវឌ្ឍ និងរៀបចំបទប្បញ្ញត្តិឱ្យស្របនឹងការវិវត្តន៍របស់បច្ចេកវិទ្យា និងកំណើននៃការប្រើប្រាស់សេវាទូទាត់សងប្រាក់នៅកម្ពុជា ដើម្បីធានាបាននូវស្ថិរភាព និរន្តរភាព កាត់បន្ថយហានិភ័យជាប្រព័ន្ធ ការពារផលប្រយោជន៍អតិថិជន ជំរុញការប្រកួតប្រជែង និងជំរុញការប្រើប្រាស់សេវាទូទាត់ជាអេឡិចត្រូនិក ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។

បច្ចុប្បន្ន ក្រៅពីកំណើននៃការប្រើប្រាស់សេវាទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជា ប្រតិបត្តិការផ្ទេរប្រាក់ចូល និងផ្ទេរប្រាក់ចេញក្រៅប្រទេសក៏កំពុងមានសកម្មភាពយ៉ាងមមាញឹក និងមានការប្រកួតប្រជែងយ៉ាងខ្លាំងផងដែរ ដោយសារការកំណត់កម្រៃសេវាសមរម្យ ការដាក់ចេញគំរូអាជីវកម្មបែបច្នៃប្រឌិតថ្មីៗ និងការបង្កើនល្បឿនទូទាត់ឆាប់រហ័សជាងមុនជាដើម។ ធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថា ការកំណត់ទំហំប្រាក់ប្រតិបត្តិការលើសេវាផ្ទេរប្រាក់ចេញ-ចូលក្រៅប្រទេសរបស់គ្រឹះស្ថាននីមួយៗពុំដូចគ្នាទេ ដោយគ្រឹះស្ថានបានកំណត់តាមគោលការណ៍រៀងៗខ្លួន។ ដូចនេះ ដើម្បីឱ្យការកំណត់ទំហំប្រាក់ប្រតិបត្តិការមានតម្លាភាពលក្ខណៈជាស្តង់ដាររួម និងក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិ ក្នុងដំណាក់កាលសាកល្បង" ដើម្បីគ្រប់គ្រងលំហូរសាច់ប្រាក់ចេញ និងចូលប្រទេសកម្ពុជា ក៏ដូចជាទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាដើម។ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់សងប្រាក់ដែលធនាគារជាតិនៃកម្ពុជាបានអនុម័តកន្លងមកមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១។

ក្នុងគោលបំណងគ្រប់គ្រងប្រតិបត្តិការសេវាទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិថ្មីៗបន្ថែមទៀត ដូចជាការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការកំណត់ពីលក្ខខណ្ឌ និងនីតិវិធីសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្នើសុំការអនុញ្ញាតជ្រើសរើសភ្នាក់ងារ គ្រប់គ្រងគណនីអាណត្តិព្យាបាល នីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងប្រកាសដែលកំណត់អំពីនីតិវិធីគ្រប់គ្រងប្រតិបត្តិការ និងប្រតិបត្តិករទីផ្សារតណាទានតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៤.១.៣. ការវិភាគ និងវាយតម្លៃសុខុមាលភាពគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

បន្ទាប់ពីផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាមានតួនាទីត្រួតពិនិត្យ និងតាមដានជាប្រចាំលើគ្រឹះស្ថានទាំងនេះ ដើម្បីរក្សាសុវត្ថិភាព និងផ្តល់ទំនុកចិត្តដល់សាធារណជនមកលើសេវាទូទាត់សងប្រាក់។ ធនាគារជាតិនៃកម្ពុជាត្រួតពិនិត្យជាប្រចាំលើ



គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណ ដោយផ្តោតលើវិធីសាស្ត្រត្រួតពិនិត្យលើហានិភ័យ (Risk Based Approach) ក៏ដូចជាការត្រួតពិនិត្យលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ (Compliance Based Approach) សំដៅកាត់បន្ថយហានិភ័យ និងធានាបានសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ការត្រួតពិនិត្យត្រូវបានបែងចែកជាពីរប្រភេទ រួមមាន ការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង។

### ក). ការត្រួតពិនិត្យលើឯកសារ

ការត្រួតពិនិត្យលើឯកសារ ជាការពិនិត្យ សិក្សា និងវាយតម្លៃលើសំណុំឯកសារស្នើសុំរបស់គ្រឹះស្ថាន និងវិភាគលើរបាយការណ៍ប្រតិបត្តិការ និងព័ត៌មានហិរញ្ញវត្ថុដែលគ្រឹះស្ថានផ្ញើជាប្រចាំមកធនាគារជាតិនៃកម្ពុជា។ ការវាយតម្លៃហានិភ័យជាលក្ខណៈមីក្រូផ្តោតសំខាន់លើសូចនាករហានិភ័យសំខាន់ៗ និងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាពីភាពរឹងមាំរបស់គ្រឹះស្ថាន ហើយសូចនាករដទៃផ្សេងទៀត ក៏ត្រូវបានប្រើប្រាស់ផងដែរទៅតាមភាពជាក់ស្តែងនៃស្ថានភាពរបស់គ្រឹះស្ថាន។ សូចនាករហានិភ័យនីមួយៗដែលត្រូវយកមកវាយតម្លៃជាលក្ខណៈមីក្រូរួមមានដូចខាងក្រោម៖

- **អភិបាលកិច្ច៖** ជាការវាយតម្លៃទៅលើភាពសមស្រប និងប្រសិទ្ធភាពនៃរចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន។ ដើម្បីវាយតម្លៃលើអភិបាលកិច្ចរបស់គ្រឹះស្ថាន គឺត្រូវពិនិត្យលើសូចនាករសំខាន់ៗ រួមមាន គណនេយ្យភាព ការចូលរួមបំពេញកាតព្វកិច្ចយ៉ាងសកម្ម និងលទ្ធផលការងាររបស់ក្រុម-ប្រឹក្សាភិបាល ក៏ដូចជាការបែងចែកមុខងារ និងភារកិច្ចរបស់សមាជិកនីមួយៗ។ ម្យ៉ាងទៀត ការវាយតម្លៃក៏ត្រូវពិនិត្យទៅលើការគោរពតាមច្បាប់ និងបទប្បញ្ញត្តិរបស់គ្រឹះស្ថានផងដែរ។ តាមរយៈនេះ គ្រឹះស្ថាននីមួយៗបានបង្កើតឡើង ដោយមានហេដ្ឋារចនាសម្ព័ន្ធ ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការ មន្ត្រីប្រតិបត្តិតាម និងថ្នាក់ដឹកនាំតាមផ្នែកនីមួយៗដែលមានបទពិសោធន៍ ចំណេះដឹង និងមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីដឹកនាំគ្រឹះស្ថាន។

- **ហានិភ័យឥណទាន៖** វាយតម្លៃផ្អែកលើផលិតផល និងសេវាដែលគ្រឹះស្ថានបានដាក់ឱ្យអតិថិជនប្រើប្រាស់ ដូចជាការឱ្យខ្ចីប្រាក់មុនជាដើម។ បន្ថែមពីនេះ ការវិនិយោគលើមូលនិធិ Trust Fund និង Counterparties Risk ដែលគ្រឹះស្ថានបានរក្សាទុកមូលនិធិរបស់គ្រឹះស្ថានក្រោមទម្រង់ជាគណនីអាណត្តិព្យាបាល (Trust Account)។ យោងតាមប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មូលនិធិដែលទទួលបានពីអតិថិជនត្រូវតម្កល់ក្នុងគណនីដោយឡែកនៅគ្រឹះស្ថានធនាគារពាណិជ្ជដែលមានរូបភាពជាគណនីអាណត្តិព្យាបាល ឬអាចវិនិយោគលើទ្រព្យសកម្មមានសុវត្ថិភាព មានហានិភ័យទាប និងមានសន្ទនីយភាពខ្ពស់ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។ គិតត្រឹមឆ្នាំ២០២២ នេះ មិនទាន់មានគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ណាមួយធ្វើការវិនិយោគលើទ្រព្យសកម្មនេះទេ។



- **ហានិភ័យសន្ទនីយភាព៖** កើតមានឡើងនៅពេលដែលគ្រឹះស្ថានអសមត្ថភាពក្នុងការបង្វិលសាច់ប្រាក់ជូនអតិថិជនរបស់ខ្លួន។ ការវាយតម្លៃហានិភ័យសន្ទនីយភាពនេះ គឺផ្តោតសំខាន់លើការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថាន ដូចជាយន្តការទូទាត់របស់គ្រឹះស្ថានជាមួយដៃគូសហការ ការគ្រប់គ្រងសមតុល្យសាច់ប្រាក់នៅក្នុងគណនីអាណត្តិព្យាបាល ដើម្បីឱ្យមានទំហំធំជាងគណនីអ៊ីវ៉ាឡេតដែលបានចេញផ្សាយជូនអតិថិជន និងការរៀបចំគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ងាយស្រួល។

- **ហានិភ័យយុទ្ធសាស្ត្រ៖** ជាការវាយតម្លៃទៅលើនិន្នាការនៃអាត្រាកំណើនអាជីវកម្មប្រចាំគ្រា (ពីមួយត្រីមាសទៅមួយត្រីមាស) និងគុណភាពផលិតផល និងសេវា ក៏ដូចជាទំហំនៃចំណែកទីផ្សារនៅក្នុងទីផ្សារទូទាត់សងប្រាក់។ ការវាយតម្លៃហានិភ័យយុទ្ធសាស្ត្រក៏ពាក់ព័ន្ធទៅនឹងការប្រៀបធៀបរវាងផែនការអាជីវកម្ម និងលទ្ធផលសម្រេចបានជាក់ស្តែង។

- **ហានិភ័យប្រតិបត្តិការ៖** ក្នុងការវាយតម្លៃហានិភ័យប្រតិបត្តិការ ត្រូវបានផ្តោតសំខាន់ទៅលើគុណភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថាន ការរក្សាប្រព័ន្ធផ្ទុកទិន្នន័យ និងដំណើរការប្រតិបត្តិការ ការដាក់ចេញនិងអនុវត្តនូវផែនការនិរន្តរភាពអាជីវកម្ម ក៏ដូចជាកត្តាខាងក្រៅផ្សេងៗជាច្រើនទៀត ដែលអាចបណ្តាលឱ្យមានការរាំងស្ទះដល់ដំណើរការជាប្រចាំរបស់គ្រឹះស្ថាន។ ការវាយតម្លៃបានពិនិត្យលើការកើតឡើងជារឿយៗនៃបញ្ហាមួយចំនួនដូចជា ករណីក្លែងបន្លំ បណ្តឹងតវ៉ារបស់អតិថិជន ការដាច់ចរន្តប្រព័ន្ធ និងករណី Cyber-Attack ជាដើម ហើយវាយតម្លៃទៅលើការឆ្លើយតប និងនីតិវិធីក្នុងការដោះស្រាយបញ្ហាទាំងនេះរបស់គ្រឹះស្ថាន។ ដើម្បីទប់ស្កាត់ហានិភ័យប្រតិបត្តិការ គ្រឹះស្ថានបានរៀបចំប្រព័ន្ធត្រៀមបម្រុងទុកដោយមានការចម្លងទិន្នន័យទុក ដែលអាចដំណើរការបានភ្លាមៗនៅពេលដែលប្រព័ន្ធចម្បងជួបប្រទះបញ្ហា។ រីឯការវាយប្រហារចូលក្នុងប្រព័ន្ធ គ្រឹះស្ថានបានទប់ស្កាត់ និងដោះស្រាយបានទាន់ពេលវេលា។

- **ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម៖** ការត្រួតពិនិត្យនឹងធ្វើការវាយតម្លៃទៅលើការអនុវត្តនីតិវិធីស្គាល់អតិថិជន (KYC) និងវាយតម្លៃថាតើយន្តការនិងនិតិវិធីដែលបង្កើតឡើងដោយគ្រឹះស្ថានមានប្រសិទ្ធភាពអាចរកឃើញ និងបង្ការប្រតិបត្តិការដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ លើសពីនេះ ការវាយតម្លៃនេះក៏ផ្តោតទៅលើវត្តមាន និងការបំពេញមុខងារ និងកាតព្វកិច្ចរបស់មន្ត្រីប្រតិបត្តិតាម ដើម្បីធានាការគោរពតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ តាមរយៈនេះ គ្រឹះស្ថានបានដាក់ចេញនូវយន្តការ និងនីតិវិធីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងអនុវត្តនីតិវិធីស្គាល់អតិថិជនមុននឹងចេញផ្សាយគណនីអ៊ីវ៉ាឡេតឱ្យអតិថិជនប្រើប្រាស់។

- **ការការពារអតិថិជន៖** ការដាក់ចេញសេចក្តីណែនាំអំពីការប្រើប្រាស់សេវា និងការផ្តល់ព័ត៌មានបានទូលំទូលាយដល់អតិថិជនក្នុងការប្រើប្រាស់សេវា ក៏ជាកត្តាសំខាន់មួយដែលធនាគារជាតិនៃកម្ពុជា



យកមកពិចារណាក្នុងការវាយតម្លៃអំពីសុខុមាលភាពរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ម៉្យាងទៀត គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទត្រូវបានរៀបចំបានត្រឹមត្រូវ។ ដូចនេះ គ្រឹះស្ថានបានដាក់ចេញនូវយន្តការការពារផលប្រយោជន៍អតិថិជន គោលការណ៍ដោះស្រាយវិវាទជូនអតិថិជនដែលការណ៍នេះគ្រឹះស្ថានអាចដោះស្រាយបញ្ហាជូនអតិថិជនបានទាន់ពេលវេលា។

- **លទ្ធភាពរកប្រាក់ចំណេញ៖** ការវាយតម្លៃផ្តោតសំខាន់លើគុណភាព និងភាពខ្លាំងនៃការរកប្រាក់ចំណូលបច្ចុប្បន្ន ព្រមទាំងវាយតម្លៃទៅលើស្ថានភាពសេដ្ឋកិច្ចដែលជះឥទ្ធិពលទៅលទ្ធភាពរកប្រាក់ចំណូលរបស់គ្រឹះស្ថាន និងបម្រែបម្រួលរវាងចំណូល និងចំណាយ។

- **ភាពគ្រប់គ្រាន់នៃដើមទុន៖** ការវាយតម្លៃអំពីភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថាន រួមមានការវាយតម្លៃទៅលើអនុបាតសន្ទនីយភាព និងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថាន។

#### ខ). ការត្រួតពិនិត្យដល់ទីកន្លែង

ការត្រួតពិនិត្យដល់ទីកន្លែង ជាការចុះត្រួតពិនិត្យដល់ទីស្នាក់ការរបស់គ្រឹះស្ថាន ដែលធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យលើឯកសារ ហើយជាកាតព្វកិច្ចមួយដ៏សំខាន់ ក្នុងការពិនិត្យរកឱ្យឃើញពីស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថាននីមួយៗ។ ការត្រួតពិនិត្យដល់ទីកន្លែង សំដៅការចុះត្រួតពិនិត្យផ្ទាល់ជាប្រចាំគ្រានៅតាមទីស្នាក់ការកណ្តាល សាខា ឬទីតាំងពាក់ព័ន្ធដទៃផ្សេងទៀតរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដោយផ្អែកលើព័ត៌មានទទួលបានពីការវាយតម្លៃលក្ខណៈមីក្រូ និងប្រភពផ្សេងៗដទៃទៀត។ ក្រៅពីការចុះត្រួតពិនិត្យដល់ទីកន្លែងដែលធ្វើឡើងតាមផែនការកំណត់ ការចុះត្រួតពិនិត្យបន្ទាន់ក៏ត្រូវបានអនុវត្តផងដែរក្នុងករណីធនាគារជាតិនៃកម្ពុជារកឃើញហានិភ័យណាមួយដែលកើតឡើងដោយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

### ៤.១.៤. សវនកម្មរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ការធ្វើសវនកម្មរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គឺដើម្បីធានាភាពត្រឹមត្រូវ និងសុចរិតនៃព័ត៌មាននិងទិន្នន័យហិរញ្ញវត្ថុដែលគ្រឹះស្ថានផ្តល់ជូនធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធ ក៏ដូចជាលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងពង្រឹងគុណភាពការងារសវនកម្មរបស់គ្រឹះស្ថាន។ ដូចនេះ ដើម្បីឱ្យកាតព្វកិច្ចនេះអនុវត្តទៅប្រកបដោយប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយសេចក្តីណែនាំស្តីពី ការជ្រើសរើសនិងការទទួលស្គាល់ស្នងការគណនេយ្យឯករាជ្យចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដោយតម្រូវឱ្យគ្រប់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវជ្រើសរើស និងស្នើសុំទទួលស្គាល់ស្នងការគណនេយ្យឯករាជ្យតាមបញ្ជីឈ្មោះដែលផ្តល់ដោយធនាគារជាតិនៃកម្ពុជា សម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថាន និងធ្វើរបាយការណ៍សវនកម្មប្រចាំឆ្នាំដែលត្រូវបោះផ្សាយជាសាធារណៈមកធនាគារជាតិនៃកម្ពុជាឱ្យបានជាទៀងទាត់ស្របតាមកាលបរិច្ឆេទ និងរយៈពេលសម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

## ៤.២. ការទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែន

ការទូទាត់សងប្រាក់និងផ្ទេរប្រាក់ឆ្លងដែន បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងក្នុងពិភពលោក ជាពិសេសក្នុងតំបន់អាស៊ាន។ ឆ្លើយតបទៅនឹងតម្រូវការចាំបាច់នេះ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈយោគយល់ និងគ្រោងចុះអនុស្សរណៈយោគយល់ជាលក្ខណៈទ្វេភាគី ជាមួយប្រទេសមួយចំនួននៅក្នុងតំបន់ដូចជា ថៃ ម៉ាឡេស៊ី វៀតណាម ឡាវ ភូមា ទីម័រ រវ៉ាន់ដា កោះសូឡូម៉ុន និងហ្វីជី ក្នុងនោះការទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជា ថៃ និងម៉ាឡេស៊ីសម្រេចបានរួចមកហើយ។ ចំពោះ ការទូទាត់រវាងប្រទេសវៀតណាម និងឡាវ គ្រោងនឹងដាក់ឱ្យដំណើរការនាពេលឆាប់ៗខាងមុខនេះ។

### ៤.២.១. ទិដ្ឋភាពទូទៅ និងការវិវត្តន៍

បន្ទាប់ពីមានការយកចិត្តទុកដាក់ខ្ពស់ពីធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងពង្រីកវិសាលភាពនៃការធ្វើប្រតិបត្តិការតាមបែបអេឡិចត្រូនិកឱ្យកាន់តែប្រសើរឡើង និងផ្តល់ទំនុកចិត្តដល់សាធារណជន យើងសង្កេតឃើញថា ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបក្នុងការផ្តល់សេវាធនាគារ និងហិរញ្ញវត្ថុរបស់គ្រឹះស្ថានកំពុងមានការប្រកួតប្រជែង និងពេញនិយមគួរឱ្យកត់សម្គាល់។ ទន្ទឹមនេះ បណ្តាក្រុមហ៊ុនផ្តល់សេវាផ្ទេរប្រាក់អន្តរជាតិបានខិតខំបង្កើនសមត្ថភាពផ្តល់សេវា ដោយផ្តោតសំខាន់លើការពង្រីកបណ្តាញទូទាត់ឱ្យស្របតាមតម្រូវការរបស់អតិថិជន និងការគ្រប់គ្រងហានិភ័យនានាពាក់ព័ន្ធនឹងផ្នែកសុវត្ថិភាពព័ត៌មានវិទ្យា និងការលាងសម្អាតប្រាក់ជាដើម។ តាមរយៈនេះ អតិថិជនដែលជានីតិបុគ្គល និងរូបវន្តបុគ្គលមានជម្រើសច្រើនក្នុងការធ្វើប្រតិបត្តិការទូទាត់ទំនិញ និងផ្ទេរប្រាក់ជាមួយដៃគូអាជីវកម្មក្រៅប្រទេស ហើយជាពិសេសសម្រួលដល់ពលករចំណាកស្រុកអាចផ្ញើប្រាក់ឱ្យក្រុមគ្រួសារបាននៅគ្រប់ទីកន្លែង គ្រប់ពេលវេលា ប្រកបដោយសុវត្ថិភាព និងបរិយាបន្ន។

ចំពោះសកម្មភាពទូទាត់សម្រាប់អាជីវកម្មអន្តរជាតិ និងការផ្ទេរប្រាក់ឱ្យក្រុមគ្រួសារនៅក្រៅប្រទេសរបស់អតិថិជនទូទៅកំពុងមានសកម្មភាពយ៉ាងមមាញឹក តាមរយៈគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលផ្តល់សេវាផ្ទេរប្រាក់អន្តរជាតិប្រកបដោយភាពច្នៃប្រឌិតថ្មីៗ រួមជាមួយការដាក់ចេញនូវកម្រៃសេវាសមរម្យ និងការបង្កើនល្បឿនទូទាត់ភ្លាមៗ។ ជាទូទៅ ការទូទាត់ឆ្លងដែនអាចប្រព្រឹត្តទៅបានយ៉ាងរលូន និងមានសុវត្ថិភាពខ្ពស់ តាមរយៈបណ្តាញផ្លូវការជាច្រើនជម្រើសអាស្រ័យលើប្រភេទប្រតិបត្តិការ និងទំហំប្រាក់ផ្ទេររបស់អ្នកប្រើប្រាស់។ បណ្តាញផ្លូវការទាំងនោះរួមមាន ប្រព័ន្ធស្វីស (SWIFT) ការតភ្ជាប់ប្រព័ន្ធជាមួយអ្នកដំណើរការតតិយភាគី ក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ ព្រមទាំងដៃគូសហការផ្ទេរប្រាក់ឆ្លងដែននៅក្រៅប្រទេសជាច្រើនជាមួយគ្រឹះស្ថាន។



បច្ចុប្បន្ន ចំនួនគ្រឹះស្ថានដែលមានបម្រើសេវាផ្ទេរប្រាក់អន្តរជាតិ តាមរយៈកិច្ចសហការជាមួយដៃគូផ្ទេរប្រាក់ក្រៅប្រទេស ដែលមានសក្តានុពលនៅលើទីផ្សារផ្ទេរប្រាក់អន្តរជាតិ និងមានអាជ្ញាប័ណ្ណត្រឹមត្រូវពីអាជ្ញាធរបន្តកើនឡើងជាលំដាប់ ហើយកម្រៃសេវាត្រូវបានគិតផ្អែកលើចន្លោះទំហំប្រាក់ផ្ទេរ ឬគិតក្នុងមួយប្រតិបត្តិការក្នុងតម្លៃជាក់លាក់ណាមួយ ដែលជាទូទៅការផ្ទេរពីគណនីទៅគណនីមានតម្លៃទាបជាងការផ្ទេរដោយពុំមានគណនី។ សម្រាប់កម្រៃសេវាផ្ទេរប្រាក់នៃកិច្ចសហការរវាងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងក្រុមហ៊ុនដៃគូផ្ទេរប្រាក់ក្រៅប្រទេស ស្ថិតក្នុងចន្លោះ ០,៦% ទៅ ៥,២% នៃទំហំប្រាក់ផ្ទេរក្នុងមួយប្រតិបត្តិការ ដោយពុំគិតលើថ្លៃសេវាផ្សេងៗទៀតនោះទេ។ ដោយឡែកសម្រាប់កម្រៃសេវាផ្ទេរប្រាក់តាមអ្នកដំណើរការតតិយភាគីស្ថិតនៅចន្លោះ ០,៣៩% ទៅ ៣% បូករួមទាំងតម្លៃ Cable Charge ជាមធ្យម ៥០ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ។ រីឯកម្រៃសេវាផ្ទេរប្រាក់តាមប្រព័ន្ធស្វីស នៅរក្សាតម្លៃ ០,១៥% នៃទំហំប្រាក់ប្រតិបត្តិការ និងរួមបញ្ចូលតម្លៃ Cable Charge ១៥ ដុល្លារអាមេរិក (តាមការកំណត់របស់ធនាគារភាគច្រើន)។

ការធ្វើប្រតិបត្តិការតាមប្រព័ន្ធស្វីសនៅតែមានការប្រើប្រាស់ច្រើនសម្រាប់ការទូទាត់ទំនិញក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិដែលមានទំហំប្រាក់ធំ ហើយអតិថិជនអាចប្រើសេវានេះបាននៅតាមបញ្ជរ ឬតាមសេវាអនឡាញរបស់ធនាគារពាណិជ្ជផងដែរ។ ទំហំប្រាក់សរុបនៃការផ្ទេរចេញតាមប្រព័ន្ធនេះនៅរក្សាចំនួនធំជាងការផ្ទេរចូល ដោយអាស្រ័យលើកត្តាសកម្មភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន។ រីឯសេវាផ្ទេរប្រាក់តាមរយៈក្រុមហ៊ុនផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែននៅក្រៅប្រទេស បន្តទទួលបានការគាំទ្រខ្ពស់លើការផ្ទេរប្រាក់ឱ្យក្រុមគ្រួសារ និងសម្រាប់ការទូទាត់អាជីវកម្មខ្នាតតូចនិងមធ្យម ដោយសារសេវានេះមានកម្រៃសេវាទាប។ អាស្រ័យហេតុនេះ ទំហំប្រតិបត្តិការតាមសេវានេះមានការកើនឡើងច្រើន និងមានទំហំប្រាក់ផ្ទេរចូលច្រើនជាងការផ្ទេរចេញ។ អតិថិជនអាចប្រើសេវានេះដើម្បីផ្ទេរ និងទទួលប្រាក់បានតាមបណ្តាបញ្ជរ ភ្នាក់ងារ និងសេវាអនឡាញរបស់គ្រឹះស្ថាន។ ក្នុងឆ្នាំ២០២២ ចំនួនប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អ្នកដំណើរការតតិយភាគី និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានចំនួនប្រមាណ ៣,២៨ លានប្រតិបត្តិការ និងមានទំហំប្រាក់ចំនួនប្រហែល ៦៤,៦០ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ២១៩,៦% នៃផ.ស.ស។



**ក្រាហ្វ ២២ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤.២.២. គោលនយោបាយគាំទ្រ

ប្រកាសស្តីពី "អ្នកដំណើរការតតិយភាគី" ត្រូវបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា សម្រាប់ធនាគារពាណិជ្ជអនុវត្តលើការផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែន តាមរយៈអ្នកដំណើរការតតិយភាគីដោយប្រើប្រាស់ទីតាំងរបស់គ្រឹះស្ថានធនាគារសម្រាប់អនុវត្តតែប្រតិបត្តិការផ្ទេរប្រាក់ និងទទួលបញ្ញាផ្ញើប្រាក់។ បន្ទាប់មក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តប្រកាសស្តីពី "ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់" សម្រាប់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលមានកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់នីតិបុគ្គល ដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់នៅកម្ពុជា។ ជាមួយគ្នានេះផងដែរ ប្រកាសខាងលើក៏ផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានអាចផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែនបាន ដោយត្រូវស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាជាមុន ហើយស្ថិតក្នុងគោលការណ៍អនុញ្ញាតបណ្តោះអាសន្នជាមុនសិន ក្នុងគោលបំណងពិនិត្យ និងតាមដានហានិភ័យដែលអាចកើតមានឡើង។ ក្នុងនាមជាអាជ្ញាធរ និងដើម្បីធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តតាមរបស់គ្រឹះស្ថាន និងបានធ្វើការតាមដានលើស្ថានភាពអាជីវកម្មរបស់គ្រឹះស្ថានជាប្រចាំ តាមរយៈការវិភាគលើរបាយការណ៍ដែលគ្រឹះស្ថានដាក់ជូនធនាគារជាតិនៃកម្ពុជា និងការចុះទៅត្រួតពិនិត្យដល់ទីតាំងរបស់គ្រឹះស្ថានផងដែរ។

ដើម្បីលើកកម្ពស់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនឱ្យកាន់តែទូលំទូលាយ និងមានកម្រៃសេវាសមរម្យ ធនាគារជាតិនៃកម្ពុជាបន្តគាំទ្រកិច្ចសហការផ្ទេរប្រាក់សាកល្បងជាមួយបណ្តាក្រុមហ៊ុនផ្ទេរ

ប្រាក់ក្រៅប្រទេស និងក្រុមហ៊ុនផ្តល់ការទូទាត់តាមប័ណ្ណអន្តរជាតិ និងការស្កេនយូអរកូដ ដែលបានឆ្លងកាត់ការពិនិត្យអំពីលទ្ធភាព និងហានិភ័យដែលអាចកើតមានឡើងសម្រាប់ការសហការនេះយ៉ាងល្អិតល្អន់។ ជាមួយគ្នានេះ ទំហំប្រាក់ប្រតិបត្តិការនៃសេវានេះ កន្លងមកត្រូវបានអនុញ្ញាតស្របនឹងការស្នើសុំរបស់គ្រឹះស្ថាន និងការកំណត់ដោយធនាគារជាតិនៃកម្ពុជា ដោយផ្អែកលើលទ្ធភាពដែលអាចគ្រប់គ្រងលើហានិភ័យនានាប៉ុណ្ណោះ។ ដើម្បីឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យប្រើសេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិ ក្នុងដំណាក់កាលសាកល្បង" ដើម្បីឱ្យការអនុវត្តរបស់គ្រឹះស្ថានស្ថិតក្នុងស្តង់ដាររួមមួយ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសក្នុងតំបន់បន្ថែមទៀត ដើម្បីឱ្យប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនកាន់តែមានភាពងាយស្រួល ក៏ដូចជាជួយសម្រួលដល់ស្ថានភាពសេដ្ឋកិច្ចក្នុងការទទួលបានសេវាផ្ទេរប្រាក់ឆ្លងដែនដែលមានតម្លៃសេវាទាប រហ័ស និងមានសុវត្ថិភាព។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចាំបាច់ត្រូវបន្តអនុវត្ត និងគោរពតាមបទប្បញ្ញត្តិដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា និងលក្ខខណ្ឌគោលការណ៍អនុញ្ញាតឱ្យបានខ្ជាប់ខ្ជួនក្នុងការផ្តល់សេវាជាមួយប្រទេសដែលមានទំនាក់ទំនងជាមួយប្រទេសកម្ពុជា។ ដៃគូសហការភាគច្រើនជាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដែលមានអ្នកវិនិយោគ អ្នកជំនួញ ភ្ញៀវទេសចរទៅមកច្រើន និងជាពិសេសប្រទេសដែលមានពលករកម្ពុជារស់នៅច្រើន មានដូចជាប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង ម៉ាឡេស៊ី ថៃ និងប្រទេសផ្សេងៗទៀត។ ក្នុងករណីគ្រឹះស្ថានមានបំណងបន្តសុពលភាពបន្ថែម ឬកែលម្អសេវា គ្រឹះស្ថានអាចស្នើសុំមកធនាគារជាតិនៃកម្ពុជាជាមុន ដើម្បីធ្វើការសិក្សា វាយតម្លៃពីលទ្ធភាពដែលអាចធ្វើទៅបាន បើពុំដូចនោះ គ្រឹះស្ថានពុំអាចដាក់ឱ្យដំណើរការសេវាជូនអតិថិជនបាននោះទេ។

### ៤.២.៣. របាយការណ៍ផ្ទេរប្រាក់ឯកជនឆ្លងដែនតាមប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ - ITRS

ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (International Transactions Reporting System - ITRS) ក្នុងឆ្នាំ២០០៣ ក្នុងគោលបំណងផ្តល់ភាពងាយស្រួល និងជាមធ្យោបាយដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់រាយការណ៍អំពីការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន។ បច្ចុប្បន្ន មានគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ៦១ កំពុងរាយការណ៍តាមរយៈប្រព័ន្ធ ITRS នេះ។ ការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន ជាការផ្ទេរប្រាក់ផ្លូវការបែបអេឡិចត្រូនិកចម្បងមួយ តាមរយៈប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ហើយការផ្ទេរប្រាក់នេះភាគច្រើនធ្វើឡើងដោយពលករចំណាកស្រុកនៅក្រៅប្រទេស។ ក្នុងឆ្នាំ២០២២ ពលករចំណាកស្រុកបានផ្ទេរប្រាក់មកក្រុមគ្រួសារពីប្រទេសកូរ៉េខាងត្បូងប្រមាណ ៥៧,៨% នៃទំហំប្រាក់ផ្ទេរឆ្លងដែនជាលក្ខណៈឯកជនសរុប ហើយសហរដ្ឋអាមេរិកចំនួន ១២,៣% និងបន្តដោយប្រទេសចិន ៣,៨% និង

ប្រទេសអូស្ត្រាលី ៣,៧%។ ធនាគារជាតិនៃកម្ពុជាដែលជាបញ្ញត្តិករ និងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលថ្មីៗប្រកបដោយនវានុវត្តន៍ ដើម្បីលើកកម្ពស់ដល់ការប្រកួតប្រជែង ក៏ដូចជារួមចំណែកធ្វើឱ្យការផ្តល់សេវាផ្ទេរប្រាក់កាន់តែមានកម្រៃទាប ងាយស្រួល ឆាប់រហ័ស និងមានតម្លាភាពសម្រាប់អតិថិជន។ សរុបមក ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលថ្មីៗទាំងនេះ ជាកត្តាដ៏សំខាន់ក្នុងការលើកទឹកចិត្តឱ្យសាធារណជនងាកមកប្រើប្រាស់សេវាផ្ទេរប្រាក់តាមរយៈបណ្តាញផ្លូវការវិញ។

**ក្រាហ្វ ២៣ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



# ៥ ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ - ច្បាប់ និងបទប្បញ្ញត្តិ

| លរ. | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១ | ច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារនៃកម្ពុជា | ១៩៩៦ |
| ២ | ច្បាប់ស្ដីពី ការគ្រប់គ្រងការប្ដូរប្រាក់ | ១៩៩៧ |
| ៣ | ច្បាប់ស្ដីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | ១៩៩៩ |
| ៤ | ច្បាប់ស្ដីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០០៥ |
| ៥ | ច្បាប់ស្ដីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ២០២០ |
| ៦ | ច្បាប់ស្ដីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ២០២០ |
| ៧ | ប្រកាសស្ដីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ | ២០០៦ |
| ៨ | ប្រកាសស្ដីពី ប្រតិបត្តិការនៃគណនីទូទាត់ | ២០០៦ |
| ៩ | ប្រកាសស្ដីពី មូលប្បទានបត្រស្តង់ដារ | ២០០៨ |
| ១០ | ប្រកាសស្ដីពី ការកំណត់លេខអត្តសញ្ញាណធនាគារ | ២០០៨ |
| ១១ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន | ២០១០ |
| ១២ | ប្រកាសស្ដីពី អ្នកដំណើរការតតិយភាគី | ២០១០ |
| ១៣ | ប្រកាសស្ដីពី ការផ្ដល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ | ២០១៤ |
| ១៤ | ប្រកាសស្ដីពី សមាជិកភាពនៃប្រព័ន្ធ FAST System និង Central Shared Switch | ២០១៦ |
| ១៥ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ | ២០១៦ |
| ១៦ | ប្រកាសស្ដីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធី Cambodian Shared Switch | ២០១៧ |
| ១៧ | ប្រកាសស្ដីពី ការគ្រប់គ្រងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ | ២០១៧ |



| លរ. | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១៨ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (FAST Payment) និងប្រព័ន្ធខេមបូខានស៊ែស្វីច (Cambodian Shared Switch) | ២០១៨ |
| ១៩ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ Retail Pay | ២០១៩ |
| ២០ | ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Retail Pay | ២០២០ |
| ២១ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ | ២០២០ |
| ២២ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង | ២០២០ |
| ២៣ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង | ២០២០ |
| ២៤ | ក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ | ២០២០ |
| ២៥ | សារាចរណែនាំស្តីពី ការពង្រឹងការអនុវត្តច្បាប់ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០១៦ |
| ២៦ | សារាចរណែនាំស្តីពី នីតិវិធីស្គាល់អត្តសញ្ញាណអតិថិជន និងការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២១ |
| ២៧ | សេចក្តីជូនដំណឹងស្តីពី កម្រៃប្រតិបត្តិការផ្ទេរប្រាក់សម្រាប់ "សេវាទូទាត់រហ័ស" (FAST Payment System) | ២០១៧ |
| ២៨ | សេចក្តីជូនដំណឹងស្តីពី កម្រៃ សោហ៊ុយ និងការពិន័យសម្រាប់ប្រព័ន្ធខេមបូខានស៊ែស្វីច | ២០១៧ |
| ២៩ | សេចក្តីជូនដំណឹងស្តីពី ការកែសម្រួលគោលនយោបាយសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System) របស់សភាផាត់ទាត់ជាតិ | ២០១៨ |
| ៣០ | សេចក្តីជូនដំណឹងស្តីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់និងសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ | ២០១៩ |
| ៣១ | សេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូខានស៊ែស្វីច | ២០២០ |
| ៣២ | សេចក្តីជូនដំណឹងស្តីពី គោលនយោបាយពាក់ព័ន្ធនឹងសមាជិកភាពប្រព័ន្ធខេមបូខាន-ស៊ែស្វីច | ២០២០ |
| ៣៣ | សេចក្តីណែនាំស្តីពី កាលបរិច្ឆេទ និងរយៈពេលសម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៤ | សេចក្តីណែនាំស្តីពី ការជ្រើសរើស និងការទទួលស្គាល់សវនករគណនេយ្យឯករាជ្យចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៥ | ឯកសារបាគង White Paper | ២០២០ |

## ឧបសម្ព័ន្ធ២ - បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង | ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង |
|---|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២៤ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ២ | ធនាគារ វីង (ខេមបូឌា) ម.ក | ២៥ | ធនាគារ តូកមីន កម្ពុជា ភីអិលស៊ី |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ២៦ | សាជីវកម្មធនាគារ កាថេយូណៃធីតកម្ពុជា ចំកាត់ |
| ៤ | ធនាគារ វឌ្ឍនៈ | ២៧ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ៥ | ធនាគារ ស្ថាបនា ភីអិលស៊ី | ២៨ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ |
| ៦ | ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ | ២៩ | ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី |
| ៧ | ធនាគារ ព្រីនស៍ ម.ក | ៣០ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៨ | ធនាគារ កាណាឌីយ៉ា ក.អ | ៣១ | ធនាគារ អេស ប៊ី អាយ លីហ្វរ ម.ក |
| ៩ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ៣២ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក |
| ១០ | ធនាគារ ភ្នំពេញពាណិជ្ជ ម.ក | ៣៣ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ១១ | ធនាគារ វិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី | ៣៤ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ |
| ១២ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣៥ | គ្រឹះស្ថាន អេស៊ា ឃែស អិចប្រេស ម.ក |
| ១៣ | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | ៣៦ | គ្រឹះស្ថាន បងឡូយ ផេមិន ម.ក |
| ១៤ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ៣៧ | គ្រឹះស្ថាន ផាយ ផេ ម.ក |
| ១៥ | ធនាគារ ហត្ថា ម.ក | ៣៨ | គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក |
| ១៦ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣៩ | គ្រឹះស្ថានធានស៊ូ អ៊ិនធើណេសិនណលថេកណូឡូជី ម.ក |
| ១៧ | ធនាគារ មេឃប៊ែង (ខេមបូឌា) ម.ក | ៤០ | គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិន សឺលូសិន ម.ក |
| ១៨ | គ្រឹះស្ថាន ស្ពីត ផេ ម.ក | ៤១ | ធនាគារ អូរៀនថល ម.ក |
| ១៩ | គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក | ៤២ | គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក |
| ២០ | គ្រឹះស្ថាន លីហ្វរ ផេប្រ៉ូ ភីអិលស៊ី | ៤៣ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក |
| ២១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ប្រាសាក់ ម.ក | ៤៤ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អម្រឹត ម.ក |
| ២២ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អេ អឹម ខេ ភីអិលស៊ី | ៤៥ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ២៣ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក | ៤៦ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មហានគរ ម.ក |



# ឧបសម្ព័ន្ធ៣ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

**គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក**
អាគារលេខ ១៥ ផ្លូវលេខ ៣៨៧ ភូមិ៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
០៩៦ ៩៦៦ ៣៣៣៣ / ០៩៦ ៨១៥ ៧៣៨៨
www.edeel.com

**គ្រឹះស្ថាន ស៊ីធែល ហ្វាយនែនសល សឺវីស ម.ក**
អាគារលេខ១៨៩ ផ្លូវលេខ៤៣២ ភូមិ៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
០១៨ ៨៨០០ ៨០០
www.bestmpay.com

**គ្រឹះស្ថាន ឃូប៊ីល ម.ក**
អាគារលេខ B3&C3-1 ផ្លូវ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០៣៨ ៣៣០០ ៨៨៨
www.coobill.com.kh

**គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក**
អាគារ Keystone (No.146) ជាន់ទី១-២-៤ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៩៩ ៦៣៩
www.truemoney.com.kh

**គ្រឹះស្ថាន លី ហួរ ផេ ប្រ៊ូ ភីអិលស៊ី**
ដីឡូត៍ ២៤៣-២៤៤ ការិយាល័យ (១៥C-៤១C) ផ្លូវ ៥៩៨ សង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
០៨៧ ៦០១ ១១១
www.lyhourpay.com

**គ្រឹះស្ថាន ស្ពីត ផេ ម.ក**
ផ្ទះលេខB48, B49 ផ្លូវបុរីឡាសែន ភូមិ១៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៧០ ៩៩៧ ៧៧៥
www.speedpayplc.com

**គ្រឹះស្ថាន អាប៊ីត្រេរី ផេយ ម.ក**
វិមានកាណាឌីយ៉ា លេខ៣១៥ ជាន់ទី២៧ មហាវិថីព្រះមុន្នីវង្ស កែងវិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០១០ ៣៧០ ៨៨៨



**គ្រឹះស្ថាន អាយផេ៨៨ (ខេមបូឌា) ម.ក**
អាគារ Orient ជាន់ទី២ (A០១-០១) ផ្លូវហាវើក កោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩០១ ៧៨៨
www.ipay88.com.kh

**គ្រឹះស្ថាន ផាយ ផេ ម.ក**
ផ្ទះលេខ២០ ផ្លូវ ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩៨៨ ៩៨៩
www.pipay.com

**គ្រឹះស្ថាន ធានស៊ូ អ៊ិនធើណេសិនណល ថេកណូឡូជី ម.ក**
អគារលេខ ៤៨-៥០ ជាន់ទី៣ ផ្លូវ ៣១០ ភូមិ ២ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០២៣ ៩៨៨ ៧៧៧
www.coolcashcam.com

**គ្រឹះស្ថាន បងឡូយ ផេមិ៉ន ម.ក**
ផ្ទះលេខ ៨៧ ផ្លូវ ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៨១ ៩៩៩ ៦១៨
www.bongloy.asia

**គ្រឹះស្ថាន អេស៊ា យៃស អិចប្រេស ម.ក**
ផ្ទះលេខ B២-០៣៥-០៣៦ ផ្លូវកោះពេជ្រ (ស្ពានឥន្ទនូ) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៨ ៦៦៦ ៦៧៨ / ០៩៩ ៦៦៦ ៦៧៨ / ០៧១ ៦៦៦ ៦៧៨
www.asiaweiluy.com.kh

**គ្រឹះស្ថាន ហួយវ៉ៃ ផេ ម.ក**
អាគារលេខ ៦២ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០២៣ ២៣១ ៩៩៩
www.7572.com

**គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិ៉ន សឹលូសិន ម.ក**
អគារលេខ២៣៤ (ROYAL K PLAZA) ជាន់ទី១៥ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០៧១ ៦៥៥ ៥៦៦៦
www.emoney.com.kh

**គ្រឹះស្ថាន ដ្រេហ្គនហ្វ្លាយ ហ្វីនថេក (ខេមបូឌា) ម.ក**
អាគារ ROSE GARDEN លេខ២៥២ ជាន់ផ្ទាល់ដី សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៨ ២១៨ ៥៥៥
www.dragonfly.com.kh

**គ្រឹះស្ថាន ដាយនែមិក ផេមិន ម.ក**
ដីឡូត៍លេខ៥៨ អាគារវែនផាក ជាន់ទី១ បន្ទប់លេខ ១៣អ៊ិន សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០២៣ ៩៨៩ ១៨៦
dpkh@dynamicg.com

**គ្រឹះស្ថាន ដាប់បែលយូ អាយ ប៊ី អេស.ខេអេច.ផេមិន សឺវីស ម.ក**
ផ្ទះលេខ១៤ ផ្លូវសភាជាតិ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៨១ ៩៩៩ ០៦៩
www.wibs-khplc.com

**គ្រឹះស្ថាន តារាសាគរ ផេ ម.ក**
ប្លុក៧៣ ជាន់ផ្ទាល់ដី អគារលេខ២ Phnom Penh City Center ផ្លូវ៦១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៩៣ ៩៣៩ ៩៧៧
www.darasakorpay.com

**គ្រឹះស្ថាន បៃ សេន ថេកណូឡជី ម.ក**
Elite Town លេខ ០៥ ផ្លូវ Stanford សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៧១ ៩៩៩ ៧៧៧៩

**គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក**
ផ្ទះលេខ៥៤B (ជាន់ផ្ទាល់ដី និងជាន់ទី១) ផ្លូវ ៩៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៩៥៥ ៥៥៥៦

**គ្រឹះស្ថាន ផារ៉ាហ្គន ផេមិន សឺវីស ម.ក**
អាគារលេខ២១៦ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១២ ៤៥៦ ២៣៧



**គ្រឹះស្ថាន ឃេស អ៊ិននើវេសិន ម.ក**
អាគារលេខ១០៥ ជាន់ទី៤ ផ្លូវ ១៩៨៤A សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០៧០ ២២២ ៧០៣
www.kessinnovation.io

**គ្រឹះស្ថាន ជីប៊ីស៊ីអាយ វេនឈ័រ ម.ក**
អាគារលេខ B2-033 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៧០ ៣៣៣ ៥៣០
www.fincy.com

**គ្រឹះស្ថាន អិលអិម ផេ ម.ក**
អាគារលេខ ៦៣៥ ជាន់ទី២ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០១០ ៨០០ ៦០២ / ០១០ ៥៣៣ ៨៨៨
www.lmpay.com

**គ្រឹះស្ថាន តាំង គួង ផេ ម.ក**
អគារលេខ៩០៤-៩០៩ មហាវិថីព្រះមុន្នីវង្ស សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
០៩៩ ២៣៣ ២៣៣
www.tangkungpay.com

**គ្រឹះស្ថាន លីន ផេ ផេមិុន សឹលូសិន ម.ក**
ផ្ទះលេខ ៩០ ៩២ និង៩៤ ជាន់ទី១ (E-1) ផ្លូវលេខ ២១៧ សង្កាត់អូឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០៩៦ ៦៧៥ ៣៥៥៤
www.lync-pay.com

**គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក**
អាគារលេខ១ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៨១ ៩៧៨ ៨៨៩ / ០៨៥ ៩៧៨ ៨៨៩
www.u-pay.com

**គ្រឹះស្ថាន ស្តារផេ ហ្វីនថេក ម.ក**
ដីឡូត៍លេខ២៧៨៧ ភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល
០៨១ ៩១៦ ១០៩

**គ្រឹះស្ថាន ឡានតុន អ៊ិនធើណេសិនណល (ខេមបូឌា) ផេមិុន សឺវីស ម.ក**
California Social House (West) លេខ ៥៧១-៥៧៥ D&E ជាន់ទី២ បន្ទប់លេខ០២
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០២៣ ៩០០ ០៩១ / ០២៣ ៩០០ ០៩១
www.lantonpay.com

**គ្រឹះស្ថាន វីង ម៉ាន់នី (ខេមបូឌា) ម.ក**
ផ្ទះលេខ ៧២១ មហាវិថីព្រះមុន្នីវង្ស ភូមិ ៩ សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

**គ្រឹះស្ថាន ឃ្លីក ផេមិុន (ខេមបូឌា) ម.ក**
DK Santuary លេខ ១២៨ EF ជាន់ទី៤ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១០ ៩២៧ ៤៥០

**គ្រឹះស្ថាន សាន់ផេ (ខេមបូឌា) ម.ក**
អាគារ Diamond Twin Tower, ជាន់ទី១៧ ផ្លូវសុភមង្គល (កោះពេជ្រ) ភូមិ១៤ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៦៧៨ ២៦៧៨

**គ្រឹះស្ថាន កៃ ហ្វូ គុង ផេមិុន ម.ក**
សណ្ឋាគារប្លាទីនអន្តរជាតិ ផ្លូវប៉ូឡូវៃ ជាន់ទី ១ និងទី២ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
០៩៣ ៩២២ ២២៩
www.cpay168.com

**គ្រឹះស្ថាន ផេយ៉ុន ម.ក**
លេខ ៣F មជ្ឈមណ្ឌល PGCT ផ្លូវលេខ ២៧៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៨៧ ៩៧៥
www.payon.com.kh

**គ្រឹះស្ថាន ជីន ហុង ជិន ថេកណូឡូជី ម.ក**
ផ្ទះលេខ ៣៨ ផ្លូវលេខ ៩៦៨ ភូមិ១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ



# ឧបសម្ព័ន្ធ៤ - គ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក

## ១. គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ២០ | ធនាគារ មេហ្គា អ៊ីនធើណេសិនណល ខមមើសល ប៊ែង ខូអិលធីឌី សាខាភ្នំពេញ |
| ២ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២១ | ធនាគារ មីហ្សូហូ អិលធីឌី |
| ៣ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ២២ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៤ | ធនាគារ ចិន | ២៣ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២៤ | ធនាគារ ហ្វីលីព ភីអិលស៊ី |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៥ | ធនាគារ ព្រីនស៍ ម.ក |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | ២៦ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៧ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៨ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ២៩ | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី |
| ១១ | សាជីវកម្មធនាគារ កាថេ យូណៃធីត (កម្ពុជា) ចំកាត់ | ៣០ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ១២ | ធនាគារ ពាណិជ្ជទីមួយ | ៣១ | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ |
| ១៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣២ | ធនាគារ សហពាណិជ្ជ ក.អ |
| ១៤ | ធនាគារ ហត្ថា ម.ក | ៣៣ | ធនាគារ វឌ្ឍនៈ |
| ១៥ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣៤ | ធនាគារ ឌីជីប៊ី ម.ក |
| ១៦ | សាខាធនាគារ អ៊ិនដាសស្ទ្រៀល ប៊ែង អហ្វ ខូរៀ ភ្នំពេញ | ៣៥ | សាខាធនាគារកសិកន ផាប់ប្លីក ខមភេនី លីមីធីត (ភ្នំពេញ) |
| ១៧ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣៦ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១៨ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | ៣៧ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក |
| ១៩ | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | ៣៨ | ធនាគារ អូរៀនថល ម.ក |

## ២. គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ១៨ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ |
| ២ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ១៩ | ធនាគារ ព្រីនស៍ ម.ក |
| ៣ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | ២០ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៤ | ធនាគារ ចិន | ២១ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២២ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៣ | ធនាគារ អេស ប៊ី អាយ លីហ្វរ ម.ក |
| ៧ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ២៤ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៥ | ធនាគារ សហពាណិជ្ជ ក.អ |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៦ | ធនាគារ វឌ្ឍនៈ |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ២៧ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ១១ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ២៨ | ធនាគារ ឌីជីប៊ី ម.ក |
| ១២ | ធនាគារ ហត្ថា ម.ក | ២៩ | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី |
| ១៣ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣០ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១៤ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក |
| ១៥ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | ៣២ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក |
| ១៦ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | ៣៣ | ធនាគារ អូរៀនថល ម.ក |
| ១៧ | ធនាគារ ហ្វីលីព ភីអិលស៊ី | | |

## ឧបសម្ព័ន្ធ៥ - ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបាគង

១. ប្រព័ន្ធបាគងមានលក្ខណៈជាប្រព័ន្ធទូទាត់សងប្រាក់កន្លោង



## ២. ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបាគង





KHQR